European Union

BMZ

Federal Ministry
for Economic Cooperation
and Development

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

vhs
DVV International

# សេចក្តីណែនាំ
# ស្តីពី
# ការប្រើប្រាស់ឧបករណ៍តាមដានគោលនយោបាយ
# សុខភាពសិក្សា



**រៀបចំដោយ**

**អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)**

**ឆ្នាំ ២០១៦**

# សេចក្ដីណែនាំ

# ស្ដីពី

# ការប្រើប្រាស់ឧបករណ៍តាមដានគោលនយោបាយសុខភាពសិក្សា

# មាតិកា


អារម្ភកថា.......................................................................... ១

គោលបំណងនៃការរៀបចំឧបករណ៍តាមដានគោលនយោបាយអប់រំ.......................... ២

សេចក្តីថ្លែងអំណរគុណ .......................................................................... ៣

សេចក្តីណែនាំស្តីពីការប្រើប្រាស់ឧបករណ៍តាមដាន............................................ ៤

ឧបករណ៍តាមដានគោលនយោបាយសុខភាពសិក្សា........................................... ៧

ឯកសារយោង៖

## អារម្ភកថា

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការ *Deutscher Volkshochschul-Verbandese.V. (DVV)* អន្តរជាតិ កំពុងអនុវត្តគម្រោង “ **កៀរគរសង្គមស៊ីវិលក្នុងការដោះស្រាយភាពខ្វះចន្លោះនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ**” ដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និង BMZ។ គម្រោងនេះមានរយៈពេល៣ឆ្នាំ ចាប់អនុវត្តពីខែមករា ឆ្នាំ២០១៦ ដល់ខែធ្នូ ឆ្នាំ២០១៨ មានគោលបំណងកែលម្អសេវាអប់រំនៅប្រទេសកម្ពុជាតាមរយៈការចូលរួមកាន់តែខ្លាំងរបស់សង្គមស៊ីវិលនៅក្នុងកិច្ចពិភាក្សា និងតាមដានការអនុវត្តគោលនយោបាយនានា។ គម្រោងនេះក៏អភិវឌ្ឍបន្ថែមនិងពង្រីកសកម្មភាពរបស់បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ជាតិ ដែលធ្វើការក្នុងវិស័យអប់រំ។

ភាពរីកចំរើននានាត្រូវបានកត់សម្គាល់នៅក្នុងការធ្វើកំណែទម្រង់វិស័យអប់រំនៅប្រទេសកម្ពុជាក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ។ គម្លាតនៅក្នុងការអនុវត្តគោលនយោបាយថ្នាក់ជាតិនៅកម្រិតមូលដ្ឋាននៅតែជាបញ្ហាប្រឈមចំពោះការផ្តល់សេវាអប់រំប្រកបដោយគុណភាព។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ គម្រោងដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុបនឹងចូលរួមពង្រឹងយន្តការអនុវត្តការងាររបស់សង្គមស៊ីវិលថ្នាក់ក្រោមជាតិ និងបង្កើនសមត្ថភាពរបស់ពួកគេក្នុងការតាមដានការផ្តល់សេវា និងការអនុវត្តគោលនយោបាយអប់រំនៅថ្នាក់មូលដ្ឋាន។

ដោយផ្អែកលើការរកឃើញតាមរយៈលំហូរព័ត៌មានពីថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិលនឹងជំរុញឱ្យចូលរួមក្នុងកិច្ចពិភាក្សាគោលនយោបាយ និងការសម្រេចចិត្តនានាដើម្បីធ្វើឱ្យការអនុវត្តគោលនយោបាយវិស័យអប់រំកាន់តែមានប្រសិទ្ធិភាពនិងប្រសិទ្ធិផល។

## គោលបំណងនៃការរៀបចំឧបករណ៍តាមដានគោលនយោបាយអប់រំ

គម្លាតនៃការរំពឹងទុករបស់គោលនយោបាយអប់រំថ្នាក់ជាតិ និងការផ្តល់សេវាអប់រំជាក់ស្តែងនៅថ្នាក់មូលដ្ឋានត្រូវបានសង្កេតឃើញនៅតាមបណ្តាខេត្តនានានៃប្រទេសកម្ពុជា។ ដើម្បីចូលរួមកាត់បន្ថយគម្លាតនេះ អង្គការសង្គមស៊ីវិល និងសហគមន៍មានតួនាទីចាំបាច់ណាស់ក្នុងការតាមដានការអនុវត្តគោលនយោបាយអប់រំថ្នាក់ជាតិនៅកម្រិតមូលដ្ឋាន និងប្រមូលព័ត៌មានទាំងនេះដើម្បីចូលរួមកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាអប់រំនៅថ្នាក់មូលដ្ឋាន ដើម្បីឆ្ពោះទៅរកការអប់រំប្រកបដោយគុណភាព។ សមិទ្ធផលនៃការបង្កើតឧបករណ៍តាមដានការអនុវត្តគោលនយោបាយអប់រំត្រូវបានរៀបចំឡើងតាមរយៈកិច្ចពិគ្រោះយោបល់ចំនួនពីរលើក ជាមួយអង្គការសង្គមស៊ីវិលដែលជាសមាជិករបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលនិងមានការចូលរួមផ្តល់យោបល់ពីនាយកដ្ឋានជំនាញដូចជានាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នាយកដ្ឋានសុខភាពសិក្សា និងនាយកដ្ឋានបឋមសិក្សានៃក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងអង្គការជំនាញដើម្បីពិនិត្យនិងកែលម្អឧបករណ៍តាមដាននេះ។ ការតាមដាន ការអនុវត្តគោលនយោបាយអប់រំថ្នាក់ជាតិអាចធ្វើទៅបានតាមរយៈការបង្កើតឧបករណ៍តាមដានគោលនយោបាយអប់រំមួយដ៏សាមញ្ញងាយស្រួលប្រើប្រាស់ និងអាចប្រមូលព័ត៌មានបានដោយបុគ្គលិកអង្គការ និងសហគមន៍។

នៅក្នុងក្របខណ្ឌនេះ គម្រោង **"កៀរគរសង្គមស៊ីវិលក្នុងការដោះស្រាយភាពខ្វះចន្លោះនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ"** នឹងបង្កើតឧបករណ៍តាមដានចំនួន៥ក្នុងរយៈពេលបីឆ្នាំ និងបណ្តុះបណ្តាលបុគ្គលិកអង្គការសង្គមស៊ីវិលក្នុងការប្រើប្រាស់ឧបករណ៍នេះដើម្បីតាមដានការអនុវត្តគោលនយោបាយអប់រំ ក៏ដូចជាការផ្តល់សេវាអប់រំនៅថ្នាក់មូលដ្ឋាន ។

ក្នុងឆ្នាំ២០១៦ ឧបករណ៍តាមដានគោលនយោបាយអប់រំចំនួនពីរត្រូវបានបង្កើតឡើង គឺឧបករណ៍តាមដានគោលនយោបាយសៀវភៅសិក្សាគោល និងឧបករណ៍តាមដានគោលនយោបាយសុខភាពសិក្សា ដោយផ្តោតជាពិសេសលើបង្គន់អនាម័យ។

## សេចក្តីថ្លែងអំណរគុណ

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការមិនមែនរដ្ឋាភិបាលជាសមាជិករបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលដែលបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់ ដើម្បីជ្រើសរើសគោលនយោបាយជាអាទិភាពក្នុងការបង្កើតឧបករណ៍តាមដាន និងផ្តល់មតិយោបល់លើសេចក្តីព្រាងនៃឧបករណ៍តាមដាន ក្នុងន័យចូលរួមចំណែកកែលម្អសេវាអប់រំនៅថ្នាក់មូលដ្ឋាន។

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលក៏សូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះមន្រ្តីជំនាញក្រសួងអប់រំ យុវជន និងកីឡា និងតំណាងអង្គការជំនាញដែលបានចូលរួមពិនិត្យ និងកែសម្រួលឧបករណ៍តាមដានគោលនយោបាយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់សហភាពអឺរ៉ុប និង BMZ ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាលក្រោមគម្រោង កៀរគរសង្គមស៊ីវិលក្នុងការដោះស្រាយភាពខ្វះចន្លោះនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ ។

យើងខ្ញុំសង្ឃឹមថាឧបករណ៍តាមដាននេះនឹងចូលរួមចំណែកក្នុងការប្រមូលព័ត៌មានទាក់ទងនឹងការ អនុវត្តគោលនយោបាយអប់រំថ្នាក់ជាតិនៅក្នុងកម្រិតមូលដ្ឋាន ក៏ដូចជាកែលម្អការផ្តល់សេវាអប់រំ ដើម្បីឆ្ពោះទៅរកការអប់រំមួយប្រកបដោយគុណភាព។

# សេចក្តីណែនាំស្តីពី
# ការប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា

## ១. អំពីឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា

ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា ជាឧបករណ៍មួយដែលត្រូវបានគេប្រើប្រាស់សម្រាប់ប្រមូលទិន្ន័យ និងព័ត៌មានទាក់ទងនឹងការប្រតិបត្តិ ទម្លាប់ការប្រើប្រាស់បង្គន់អនាម័យ ការលាងសម្អាតដៃ ស្ថានភាពសម្ភារៈបរិក្ខារបង្គន់ សម្ភារៈសម្រាប់លាងដៃ និងការថែទាំ។ ចំពោះទិន្ន័យ និងព័ត៌មានដែលទទួលបានពីសាលារៀនគោលដៅនីមួយៗអាចចង្អុលបង្ហាញ ពីកំរិតនៃការអនុវត្តគោលនយោយបាយ។ ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា អាចត្រូវបាន គេចាត់ទុកថាជាឧបករណ៍ **Baseline and End line tools** ដែលប្រើប្រាស់សម្រាប់តាមដានភាពរីកចំរើនផ្នែកខ្លះរបស់សមាសភាគទី៣នៃសាលាកុមារមេត្រី ។

## ២. ដំណើរការនៃការបង្កើតឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា

- កំណត់បញ្ហាសំខាន់ៗទាក់ទងវិស័យអប់រំដែលនឹងកំពុងកើតឡើងនៅមូលដ្ឋានជាមួយអង្គការសមាជិក
- ពិនិត្យឯកសារដែលមានស្រាប់និងឯកសារពាក់ព័ន្ធ
- ពិភាក្សាផ្ទៃក្នុងរវាងបុគ្គលិក និងថ្នាក់ដឹកនាំអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអង្គការសមាជិក និងបើកកិច្ចពិភាក្សាដើម្បីទទួលបានការកែលម្អលើឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា ។
- រៀបចំការអនុវត្តសាកល្បងលើការប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សានៅតាមមូលដ្ឋានជាមួយសមាជិក ។
- រៀបចំសិក្ខាសាលាណែនាំពីរបៀបប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សាជាមួយសមាជិក ។
- តាមដាន និងជួយគាំទ្របន្ថែមលើការប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សាជាមួយសមាជិក ។

## ៣.ការប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា

ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា នៅកំរិតបឋមសិក្សាអាចប្រើប្រាស់ដោយអ្នកសិក្សាស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ នាយកសាលា គណៈកម្មការទ្រទ្រង់សាលារៀន ក្រុមប្រឹក្សាឃុំសង្កាត់ អ្នកធ្វើការអភិវឌ្ឍសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សានេះ អាចយកទៅប្រើប្រាស់ក្នុងពេលណាមួយនៃឆ្នាំសិក្សាណាមួយក៏បាន ។

## ៤.វិធីសាស្រ្តនៃការប្រើប្រាស់ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា

អ្នកប្រើប្រាស់កម្រងសំណួរត្រូវយល់ច្បាស់ពីខ្លឹមសារដែលមានកំណត់ក្នុងកម្រងសំណួរ ត្រូវប្រើពាក្យពេចន៍សាមញ្ញ ខ្លី ងាយយល់ ពេលជួបជាមួយលោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សានុសិស្សតាមសាលា នីមួយៗ។ ការអង្កេតនឹងត្រូវបានយកអនុវត្តដើម្បីទទួលបានទិន្ន័យ និងព័ត៌មានបន្ថែម ។ ក្នុងករណី ការអង្កេតមានភាពមិនច្បាស់លាស់ ត្រូវធ្វើការសាកសួរបន្ថែមដើម្បីទទួលបានទិន្ន័យ និងព័ត៌មានអោយបានត្រឹមត្រូវ និងច្បាស់លាស់។ អ្នកប្រើប្រាស់កម្រងសំណួរនេះមិនត្រូវបង្ខើបចម្លើយនាំមុខដែលជាហេតុធ្វើឲ្យមានភាពលំអៀងនូវទិន្ន័យ និងព័ត៌មានដែលទទួលបាន។ ជាការប្រសើរអ្នកប្រើប្រាស់កម្រងសំណួរនេះមិនត្រូវប្រើប្រាស់ម៉ោងសិក្សាសម្រាប់សួរ និងសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សានុសិស្សឡើយ។ ពេលសួរសំណួរនីមួយៗទៅកាន់សិស្សានុសិស្ស យើងត្រូវ កត់ត្រាចំនួនអ្នកផ្តល់ចំលើយនៅក្នុងជួរឈរ (column) មាន ឬ គ្មាន ។

កម្រងសំណួរនេះបែងចែកជាពីរផ្នែកគឺ **ផ្នែករឹង** (សំដៅលើសម្ភារៈបរិក្ខារបង្គន់ និងសម្ភារៈសម្រាប់លាងដៃ) **និងផ្នែកទន់** (សំដៅលើការប្រតិបត្តិ ទម្លាប់ការប្រើប្រាស់បង្គន់ ការលាងសម្អាតដៃ និងការថែទាំ) ។

## វិធីសាស្ត្រសួរសំណួរ

☞ សូមណែនាំខ្លួនឯង និងគោលបំណង

សួស្តីប្អូនៗ ខ្ញុំឈ្មោះ ...................................... .ជាបុគ្គលិកអង្គការ . មានបំណងស្វែងយល់ពីព័ត៌មានដែលទាក់ទងនឹងសម្ភារៈបរិក្ខារបង្គន់អនាម័យ សម្ភារៈសម្រាប់លាងដៃ ការប្រតិបត្តិ ទម្លាប់ការប្រើប្រាស់បង្គន់អនាម័យ ការលាងសម្អាតដៃ និងការថែទាំបង្គន់អនាម័យ និងកន្លែងលាងសម្អាតដៃ របស់ប្អូនៗសិស្សានុសិស្សក្នុងសាលារៀននេះ ។ ព័ត៌មានដែលទទួលបាននឹងត្រូវយកទៅផ្ទៀងផ្ទាត់ជាមួយគោលនយោបាយសុខភាពសិក្សាដែលផ្តោតសំខាន់ទៅលើការប្រើប្រាស់បង្គន់អនាម័យ និងការលាងសម្អាតដៃនៅតាមសាលារៀន ។

ការសម្ភាសន៍នេះមានរយៈពេលពី ៨ ទៅ ១៥នាទី ហើយគ្រប់ព័ត៌មានដែលប្អូនៗផ្តល់ឱ្យនឹងត្រូវរក្សាជាការសម្ងាត់។ គ្រប់ចម្លើយពិតរបស់ប្អូនៗមានប្រយោជន៍សំរាប់ជួយកែលម្អការអនុវត្តគោលនយោបាយសុខភាពសិក្សាអោយបានប្រសើរឡើង ។

## ៥.ការជ្រើសរើសសំណាក

ដើម្បីឲ្យមានភាពងាយស្រួល និងចំណាយពេលវេលាតិចក្នុងការសម្ភាសន៍ ការជ្រើសរើសសំណាកសម្រាប់សម្ភាសន៍សិស្សានុសិស្ស គួរត្រូវបានគេយកយ៉ាងហោចណាស់ ២៥% នៃសិស្សសរុបក្នុងថ្នាក់នីមួយៗ។ សម្រាប់សាលាបឋមសិក្សាដែលមានគ្រប់កំរិតថ្នាក់ យើងត្រូវជ្រើសរើសសំណាកយ៉ាងហោចណាស់ ៣កំរិតផ្សេងៗគ្នា ។ ប៉ុន្តែសម្រាប់សាលាបឋមសិក្សាដែលមិនមានគ្រប់កំរិតថ្នាក់ យើងអាចជ្រើសរើសសំណាកត្រឹមតែ ២កំរិតផ្សេងៗគ្នាក៏បានដែរ ។ ជាការប្រសើរការជ្រើសរើស សំណាកសម្ភាសន៍ត្រូវយកចិត្តទុកដាក់លើតុល្យភាពរវាងកុមារា និងកុមារី ។

## ឧបករណ៍តាមដានការអនុវត្តគោលនយោបាយសុខភាពសិក្សា

European Union
BMZ Federal Ministry for Economic Cooperation and Development
គណៈជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP
vhs DVV International

ឈ្មោះអ្នកចុះសម្ភាសន៍ ៖ □□□□□□□□□□□ លេខទូរស័ព្ទ ៖ □□ កាលបរិច្ឆេទ ៖ □□

**សំណួរសម្រាប់នាយក/នាយិកា ឬគណៈកម្មការគ្រប់គ្រងសាលា ៖**

ឈ្មោះសាលា ៖ □□□□□□□ ..................................... ឃុំ/សង្កាត់៖......................... ស្រុក/ក្រុង ៖........................... ខេត្ត ៖...............

ចំនួនសិស្សសរុប ៖..................... សិស្សស្រី ៖ ............. ចំនួនគ្រូសរុប ៖...................... ចំនួនអ្នកគ្រូ ៖.............

ចំនួនសិស្សពិការសរុប ៖................. សិស្សស្រី ៖ ............. ឆ្នាំសិក្សា ៖.............................

| កម្រងសំណួរ | | មាន | គ្មាន | កំណត់សម្គាល់ |
|---|---|---|---|---|
| I. | ការសង្កេតដោយអ្នកសម្ភាសន៍ ៖ អនាម័យនៅសាលារៀន (បង្គន់) | | | |
| ១ | តើមានបង្គន់អនាម័យសម្រាប់លោកគ្រូ អ្នកគ្រូប្រើប្រាស់ដែរឬទេ ? | | | |
| ២ | តើបង្គន់អនាម័យមានបែងចែកសំរាប់លោកគ្រូ និងអ្នកគ្រូដែរឬទេ | | | |
| ៣ | តើមានបង្គន់អនាម័យសម្រាប់សិស្សានុសិស្សប្រើប្រាស់ដែរឬទេ ? | | | |
| ៤ | តើមានការបែងចែកបង្គន់សម្រាប់សិស្សប្រុសនិងសិស្សស្រី ដែរឬទេ? | | | |
| ៥ | តើមានបង្គន់អនាម័យ និងបង្គន់នោមគ្រប់គ្រាន់សម្រាប់សិស្សប្រុសដែរឬទេ ? | | | *សិស្សប្រុសចំនួន១០០នាក់ ត្រូវមានបង្គន់ចំនួន២ និង បង្គន់នោម ចំនួន៣* |
| ៦ | តើមានបង្គន់អនាម័យ គ្រប់គ្រាន់សម្រាប់សិស្សស្រី ដែរឬទេ ? | | | *សិស្សស្រី ចំនួន១០០ នាក់ ត្រូវមានបង្គន់ចំនួន ៣* |
| ៧ | តើបង្គន់អនាម័យមានសង់ជម្រាល និងបង្កាន់ដៃត្រឹមត្រូវសម្រាប់សិស្សពិការដែរឬទេ ? | | | |
| ៨ | តើសិស្សានុសិស្សមានភាពងាយស្រួលក្នុងការដើរទៅរកបង្គន់អនាម័យដែរឬទេ ? | | | *ស្ថានភាពផ្លូវ និងចំងាយ ទៅកាន់បង្គន់អនាម័យ* |
| ៩ | តើប្អូនមានទម្លាប់ក្នុងការប្រើប្រាស់បង្គន់ ដែរឬទេ ? | | | |
| ១០ | តើបង្គន់អនាម័យបានអនុញ្ញាតឲ្យប្រើប្រាស់ រាល់ម៉ោងសិក្សាដែរឬទេ ? | | | |
| ១១ | តើមានការបែងចែកវេនសម្អាតបង្គន់ បានទៀងទាត់ ដែរឬទេ ? | | | |
| ១២ | តើបង្គន់មានអនាម័យ ដែរឬទេ ? | | | |
| ១៣ | តើបង្គន់មានទឹកប្រើប្រាស់គ្រប់គ្រាន់ ពេញមួយឆ្នាំសិក្សា ដែរឬទេ ? | | | |
| ១៤ | តើមានកន្លែងលាងសំអាតដៃ ដែរឬទេ ? | | | |
| ១៥ | តើមានសាប៊ូនៅកន្លែងលាងដៃ ដែរឬទេ ? | | | សូមសង្កេត |
| ១៦ | តើមានទឹកស្អាតសម្រាប់បរិភោគ ដែរឬទេ ? (ទឹកដាំពុះ ទឹកចម្រោះ ទឹកបរិសុទ្ធ ជាដើម) | | | សូមសង្កេត |
| ១៧ | តើមានការបង្រៀន ឬផ្សព្វផ្សាយអំពីការអប់រំសុខភាព និងអនាម័យ ដែរឬទេ | | | |

European Union

BMZ Federal Ministry for Economic Cooperation and Development

NGO EDUCATION PARTNERSHIP

vhs DVV International

## Checklist for school health policy

Name of interviewer: ………………………. Phone number: ……………………………………. Date: …………………..

**<u>Questions for school principle or School management Committee</u>**

Name of School: ………… Commune: ………… District: …………………… Province: …………

Total students: ………… Female: ………… Total teachers: …………. Female: ……………

Children with disability: ………. Female:…………. Academic year: …………

| | Questions | Yes | No | Remarks |
|---|---|---|---|---|
| | **Toilet, Safe water and hand-washing at school** | | | |
| 1 | Are there toilets teachers? | | | |
| 2 | Are there separate toilet facilities for male and females teachers? | | | |
| 3 | Are there toilets for students? | | | |
| 4 | Are there separate toilet facilities for male and females students? | | | |
| 5 | Are there sufficient toilet and urinals for male students?<br>***National standard: 2 latrines and 3 urinals for 100 male students*** | | | |
| 6 | Are there sufficient toilets for female students?<br>***National standard: 3 toilet for 100 female students*** | | | |
| 7 | Are toilets accessible to persons with disability? | | | |
| 8 | Are toilets easy to get access? | | | Way to toilet |
| 9 | Are toilets open during school opening? | | | |
| 10 | Do you have habit to use toilet? | | | |
| 11 | Do you have regular schedule for cleaning? | | | |
| 12 | Are toilets clean? | | | |
| 13 | Is there enough water a whole year for toilets? | | | |
| 14 | Is there place for washing hand? | | | |
| 15 | Is there soap at the hand-washing place? | | | *observation* |
| 16 | Is there drinking water at school (boiled water, filter water, potable water etc)> | | | |
| 17 | Is health education (sanitation and hygiene) taught /disseminated at school? | | | *observation* |

# <u>ឯកសារយោង</u>

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលការណ៍ណែនាំអនុវត្ត
# លក្ខខណ្ឌអប្បបរមា
# ស្តីពី
# ទឹកស្អាត និងអនាម័យ តាមសាលារៀន

**នាយកដ្ឋានសុខភាពសិក្សា**

ឆ្នាំ២០១៦

# បញ្ជីអក្សរកាត់

| | |
|---|---|
| CwD | កុមារពិការ |
| CIP | ផែនការវិនិយោគឃុំ សង្កាត់ |
| DOE | ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ |
| DP | ដៃគូអភិវឌ្ឍន៍ |
| DTMT | ក្រុមបំប៉ន និងពិនិត្យតាមដានក្រុង ស្រុក ខណ្ឌ |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| ESP | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| LA | អាជ្ញាធរមូលដ្ឋាន |
| MHM | ការគ្រប់គ្រងអនាម័យខ្លួនប្រាណពេលមានរដូវ |
| M&E | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| O&M | ការប្រើប្រាស់ និងការថែទាំ |
| POE | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RWSSH | ការផ្គត់ផ្គង់ទឹកនៅជនបទ អនាម័យបរិស្ថាន និងអនាម័យខ្លួនប្រាណ |
| SIP | ផែនការកែលម្អសាលារៀន |
| SDG | គោលដៅអភិវឌ្ឍន៍ដោយចីរភាព |
| SDP | ផែនការអភិវឌ្ឍន៍សាលារៀន |
| SHD | នាយកដ្ឋានសុខភាពសិក្សា |
| SSC | គណៈកម្មការទ្រទ្រង់សាលារៀន |
| ToR | លក្ខខណ្ឌការងារ ឬតួនាទី និងភារកិច្ច |
| UNICEF | អង្គការមូលនិធិសហប្រជាជាតិសម្រាប់កុមារ |
| WASH | ទឹកស្អាត និងអនាម័យ |
| WFP | អង្គការកម្មវិធីស្បៀងអាហារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |
| WinS | ទឹកស្អាត និងអនាម័យ តាមសាលារៀន |

# មាតិកា

បញ្ជីអក្សរកាត់

មាតិកា

អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

ផ្នែកទី១ ៖ គោលការណ៍ទូទៅ

១.១. សេចក្តីផ្តើម....................ទំព័រ ១

១.២. គោលបំណង....................ទំព័រ ២

១.៣. លក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន.ទំព័រ ៣

ផ្នែក ទី២ ៖ គោលការណ៍ណែនាំអនុវត្ត

២.១. ទឹកស្អាតសម្រាប់ទទួលទាន....................ទំព័រ ៧

២.២. បង្គន់អនាម័យ និងបង្គន់នោម....................ទំព័រ ៨

២.៣. បរិក្ខារលាងសម្អាតដៃ....................ទំព័រ ៩

២.៤. បរិស្ថាន និងសុវត្ថិភាព....................ទំព័រ ១០

ផ្នែកទី៣ ៖ គោលការណ៍វាយតម្លៃ

៣.១. ការពិនិត្យតាមដាន....................ទំព័រ ១១

៣.២. ការវាយតម្លៃសាលារៀនចំណាត់ថ្នាក់ ផ្កាយ ....................ទំព័រ ១២

តារាងទី១. កម្រងសំណួរសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ........ទំព័រ ១៣

តារាងទី២. ការបូកសរុប វាយតម្លៃចំណាត់ថ្នាក់សាលារៀន....................ទំព័រ ១៧

៣.៣. ភារកិច្ច និងការទទួលខុសត្រូវ

ក. ក្រុមការងារថ្នាក់ជាតិ ស្តីពីទឹកស្អាត និងអនាម័យ....................ទំព័រ ១៨

ខ. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត....................ទំព័រ ១៨

គ. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ..............ទំព័រ ១៩

ឃ. គណៈគ្រប់គ្រងសាលារៀន....................ទំព័រ ១៩

ង. គ្រូបន្ទុកសុខភាពសិក្សា....................ទំព័រ ១៩

ច. ក្រុមប្រឹក្សាយុវជន ឬក្រុមប្រឹក្សាកុមារ....................ទំព័រ ២០

ឆ. គណៈកម្មការទ្រទ្រង់សាលារៀន និងមាតាបិតាសិស្ស...........ទំព័រ ២០

## អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា មានមហិច្ឆិតា ក្នុងការផ្លាស់ប្ដូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ក្នុងឆ្នាំ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍជាតិ។ កុមារ យុវជន និងមនុស្សពេញវ័យត្រូវទទួលបានការសិក្សា និងការអប់រំពេញមួយជីវិត ដែលមានភាពពាក់ព័ន្ធ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារប្រកបដោយគុណភាពខ្ពស់។ ការអប់រំត្រូវផ្ដោតលើការកសាងជំនាញ និងការផ្ដល់ឱកាសដល់សិស្ស និស្សិតគ្រប់រូបក្នុងការទទួលបានជំនាញបច្ចេកទេស និងជំនាញឯកទេសផ្សេងៗ ដើម្បីសម្រេចចិត្តបានក្នុងការអភិវឌ្ឍដែលផ្ដល់អត្ថប្រយោជន៍ពេញលេញដល់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ទីតាំងភូមិសាស្ត្រ។

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់សុខភាពនៅតាមសាលារៀន ក្នុងនោះក៏បានអភិវឌ្ឍគោលនយោបាយ ស្ដីពីសុខភាពសិក្សា និងគោលនយោបាយមួយចំនួនទៀត ក្នុងបំណងពង្រឹងសេវាសុខភាពតាមសាលារៀន ដូចជាការអប់រំបង្ការជំងឺឆ្លង ជំងឺមិនឆ្លង សុវត្ថិភាព និងសុខុមាលភាពចំណីអាហារ អាហារូបត្ថម្ភ ការពង្រឹងបរិស្ថានសិក្សា ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពទឹកស្អាត និងអនាម័យនៅតាមសាលារៀន ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍ផងដែរ។

"គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្ដីពីទឹកស្អាត និងអនាម័យតាមសាលារៀន" នេះ ជាសមិទ្ធផលថ្មីមួយទៀត ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ។ ឯកសារនេះ ណែនាំពីជំហាន និងសកម្មភាពសាមញ្ញៗ ទាក់ទងនឹងការលើកកម្ពស់កម្មវិធីទឹកស្អាត និងអនាម័យ ដែលត្រូវអនុវត្តផ្ទាល់ដោយសាលារៀន ក្នុងបំណងកាត់បន្ថយអត្រាឆ្លងជំងឺផ្សេងៗ ពិសេសជំងឺរាក និងជំងឺរលាកផ្លូវដង្ហើម ព្រមទាំងកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមយ៉ាងមុតមាំចំពោះការយកចិត្តទុកដាក់របស់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍ ក្នុងការចូលរួមអនុវត្តគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្ដីពីទឹកស្អាត និងអនាម័យតាមសាលារៀន ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

# សេចក្តីថ្លែងអំណរគុណ

សូមគោរពថ្លែងអំណរគុណចំពោះ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា គ្រប់លំដាប់ថ្នាក់ ដែលបានគាំទ្ររាល់កិច្ចដំណើរការអភិវឌ្ឍ និងផ្តល់យោបល់លើឯកសារ **"គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌ អប្បបរមា ស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន"** នេះ រហូតបានសម្រេចជាផ្លូវការ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការមូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) ដែលបានជួយគាំទ្រទាំងបច្ចេកទេស និងថវិកាក្នុងដំណើរការអភិវឌ្ឍគោលការណ៍ណែនាំនេះ។ ជាមួយគ្នានេះ ក៏សូមថ្លែងអំណរគុណចំពោះក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល អង្គការ GIZ អង្គការសុខភាពពិភពលោក (WHO) អង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត ដែលបានចូលរួមផ្តល់យោបល់ ក្នុងកិច្ចដំណើរអភិវឌ្ឍខ្លឹមសារនៃគោលការណ៍ណែនាំនេះ។

ទន្ទឹមនឹងនេះ សូមថ្លែងអំណរគុណ និងកោតសរសើរចំពោះការយកចិត្តទុកដាក់របស់បុគ្គលិកអប់រំនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ឆ្នាំង កំពត និងខេត្តតាកែវ ដែលបានចូលរួមសហការអនុវត្តសាកល្បង និងផ្តល់យោបល់កែលម្អឯកសារនេះ ឱ្យកាន់តែមានអត្ថន័យគ្រប់ជ្រុងជ្រោយ ងាយស្រួលអនុវត្ត និងស្របតាមបរិបទគ្រឹះស្ថានសិក្សានៅកម្ពុជា។

## ផ្នែកទី ១ ៖ គោលការណ៍ទូទៅ

### ១.១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តនូវគោលនយោបាយជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យកាលពីឆ្នាំ២០០៣ ដោយកំណត់នូវទស្សនវិស័យ នៅឆ្នាំ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ២០១៤-២០២៥ ក្នុងគោលបំណងធ្វើឱ្យសេវាទឹកស្អាត និងអនាម័យជនបទមានភាពប្រសើរឡើង និងប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកគាំទ្រ ដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ។

ដោយយល់យ៉ាងច្បាស់ពីផលប៉ះពាល់អវិជ្ជមាននៃកង្វះទឹកស្អាត និងអនាម័យ ក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវផលប៉ះពាល់ទាំងនេះ ដោយបានបញ្ចូលសកម្មភាពលើកកម្ពស់ទឹកស្អាត និងអនាម័យទៅក្នុងផែនការយុទ្ធសាស្ត្រអប់រំ ២០១៥-២០១៨ និងកំណត់សូចនាករសម្រាប់វាស់វែងការរីកចម្រើនប្រចាំឆ្នាំ ដើម្បីឆ្ពោះទៅសម្រេចបាន១០០% ត្រឹមឆ្នាំ២០២៥ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ដើម្បីជំរុញការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យ ឈានទៅសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍ គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន សម្រាប់ណែនាំដល់បុគ្គលិកអប់រំថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ឱ្យចូលរួមអនុវត្តជាជំហានៗ ដើម្បីធ្វើឱ្យស្ថានភាពទឹកស្អាត និងអនាម័យតាមសាលារៀនឆ្លើយតបបានតាមតម្រូវការជាមូលដ្ឋានរបស់បុគ្គលិកអប់រំ និងអ្នកសិក្សា ក្នុងបំណងកាត់បន្ថយអត្រាឆ្លងជំងឺផ្សេងៗ ពិសេសជំងឺរាក និងជំងឺរលាកផ្លូវដង្ហើម ព្រមទាំងកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភផងដែរ។

### ១.២ .គោលបំណង

គោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្ដីពីទឹកស្អាត និងអនាម័យតាមសាលារៀន មានគោលបំណងពង្រឹង និងធ្វើឱ្យប្រសើរឡើងកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀន តាមរយៈការអនុវត្តសកម្មភាពជាជំហានៗ តាមលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

លក្ខខណ្ឌ ទី១ ៖ ទឹកសម្រាប់ទទួលទាន

លក្ខខណ្ឌ ទី២ ៖ បង្គន់អនាម័យ និងបង្គន់នោម

លក្ខខណ្ឌ ទី៣ ៖ បរិក្ខារលាងសម្អាតដៃ

លក្ខខណ្ឌ ទី៤ ៖ បរិស្ថាន និងសុវត្ថិភាព

លក្ខខណ្ឌទាំងនេះ បង្កើតបរិយាកាសប្រកបដោយសុវត្ថិភាព និងផាសុកភាពដល់បុគ្គលិកអប់រំ និងអ្នកសិក្សា ក្នុងការបំពេញភារកិច្ចគរុកោសល្យបង្រៀន និងរៀនបានពេញលេញ ពិសេសប្រែក្លាយខ្លឹមសារ និងចំណេះដឹងមុខវិជ្ជាអប់រំសុខភាពឱ្យក្លាយជាសកម្មភាពអនុវត្តជាក់ស្តែង ដើម្បីជាទម្លាប់ល្អក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

## ១.៣ .លក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យ នៅតាមសាលារៀន

| លរ. | លក្ខខណ្ឌ | (★)<br>សាលារៀន ផ្កាយមួយ | (★★)<br>សាលារៀន ផ្កាយពីរ | (★★★)<br>សាលារៀន ផ្កាយបី |
|---|---|---|---|---|
| ១ | ទឹកស្អាតសម្រាប់ទទួលទាន | • សិស្សទាំងអស់មានទឹកស្អាតសម្រាប់ទទួលទាននៅសាលារៀន | | |
| | | • សិស្សទាំងអស់មានទឹកស្អាតសម្រាប់ទទួលទានយ៉ាងតិច ៥០០មីលីលីត្រក្នុងមួយវេនសិក្សា ដោយយកមកពីផ្ទះ ឬប្រភពផ្សេងទៀត។ | • ទឹកស្អាតសម្រាប់ទទួលទានបានផ្តល់ដោយសាលារៀន ប៉ុន្តែការផ្គត់ផ្គង់មិនទាន់មានភាពទៀងទាត់ ហើយសិស្សចាំបាច់យកទឹកស្អាតពីប្រភពផ្សេងៗទៀត ដូចជាយកពីផ្ទះ ឬពីប្រភពផ្សេងទៀត។ | • សាលារៀនមានផ្តល់ទឹកស្អាតសម្រាប់ទទួលទានដល់សិស្សទាំងអស់នៅគ្រប់វេនសិក្សា។ |
| ២ | បង្គន់អនាម័យ និងបង្គន់នោម | • សិស្សអាចប្រើប្រាស់ **បង្គន់អនាម័យ** គ្រប់ពេលក្នុងវេនសិក្សា | | |
| | | • សាលារៀនមានបង្គន់អនាម័យយ៉ាងតិចមួយសម្រាប់សិស្សប្រុស និងមួយសម្រាប់សិស្សស្រី។ | • សាលារៀនមានបង្គន់អនាម័យលើសពីមួយសម្រាប់សិស្សប្រុស និងលើសពីមួយសម្រាប់សិស្សស្រី<br>• សាលារៀនមានបង្គន់ | • សាលារៀនមានបង្គន់អនាម័យដែលបំពេញតាមស្តង់ដារជាតិ គឺមានបង្គន់អនាម័យ២ និងបង្គន់នោម៣ សម្រាប់សិស្សប្រុស១០០នាក់ និងបង្គន់អនាម័យ៣ សម្រាប់ |

| ល.រ. | លក្ខខណ្ឌ | (★)<br>សាលារៀន ផ្កាយមួយ | (★★)<br>សាលារៀន ផ្កាយពីរ | (★★★)<br>សាលារៀន ផ្កាយបី |
|---|---|---|---|---|
| | | | អនាម័យយ៉ាងតិចមួយដែលកុមារពិការកាយសម្បទាអាចប្រើប្រាស់បាន យ៉ាងហោចមានជម្រាល។ | សិស្សស្រី១០០នាក់<br>• សាលារៀនមានទឹកសម្រាប់ធ្វើការលាងសម្អាត ដែលយកមកពីប្រភពទឹកដែលបានកែលម្អ<br>• សាលារៀនមានសំឡីអនាម័យសម្រាប់សិស្សស្រី ប្រើប្រាស់ពេលត្រូវការបន្ទាន់<br>• បង្គន់អនាម័យសិស្សស្រី មានធុងសំរាម សម្រាប់គ្រប់គ្រងអនាម័យពេលមករដូវ។ |
| ៣ | បរិក្ខារលាងសម្អាតដៃ | • សិស្សគ្រប់គ្នាអាចប្រើប្រាស់បរិក្ខារលាងសម្អាតដៃ និងសាប៊ូ | | |
| | | • សាលារៀនមានបរិក្ខារលាងសម្អាតដៃនៅជិតបង្គន់អនាម័យ ឬនៅជិតបន្ទប់រៀន។ | • សាលារៀនមានបរិក្ខារលាងសម្អាតដៃជាក្រុមយ៉ាងតិចមួយ<br>• សាលារៀនមានកាលវិភាគ | • បរិក្ខារលាងសម្អាតដៃជាច្រើនទៀតអាចប្រើប្រាស់សម្រាប់សកម្មភាពលាងសម្អាតដៃប្រចាំថ្ងៃ<br>• សិស្សគ្រប់រូបចូលរួមនៅក្នុង |

| លរ. | លក្ខខណ្ឌ | (★)<br>សាលារៀន ផ្កាយមួយ | (★★)<br>សាលារៀន ផ្កាយពីរ | (★★★)<br>សាលារៀន ផ្កាយបី |
|---|---|---|---|---|
| | | | សម្រាប់ការលាងសម្អាតដៃជាក្រុមប្រចាំថ្ងៃ។ | សកម្មភាពលាងសម្អាតដៃ ជាក្រុមជារៀងរាល់ថ្ងៃ<br>• សិស្សគ្រប់រូបចូលរួមដុសសម្អាតធ្មេញជារៀងរាល់ថ្ងៃ<br>• ទឹកប្រើប្រាស់ត្រូវយកពីប្រភពទឹកដែលបានកែលម្អ។ |
| ៤ | បរិស្ថាន និងសុវត្ថិភាព | • សិស្សទាំងអស់ចូលរួមសម្អាតបរិវេណសាលារៀន បន្ទប់រៀន បង្គន់អនាម័យ និងបរិក្ខារលាងសម្អាតដៃ<br>• គ្មានសំរាមក្នុងបរិវេណសាលារៀន និងបន្ទប់រៀន | | |
| | | • សាលារៀនមានធុងសំរាមយ៉ាងតិចមួយសម្រាប់ដាក់សំរាម ដែលបានប្រមូល។ | • សាលារៀនមានធុងសំរាមយ៉ាងតិច២ ប្រភេទ គឺធុងសំរាមសម្រាប់ដាក់ ***សំណល់សរីរាង្គ*** និងធុងសំរាមសម្រាប់ដាក់ ***សំណល់ផ្សេងៗ***។ | • សាលារៀនមានធុងសំរាម ៣ ប្រភេទ គឺធុងសំរាមសម្រាប់ដាក់ ***សំណល់សរីរាង្គ*** ធុងសំរាមសម្រាប់ដាក់ ***សំណល់ផ្សេងៗ*** និងធុងសំរាមសម្រាប់ដាក់ ***សំណល់កែច្នៃ***<br>• សាលារៀនមានរបងព័ទ្ធជុំវិញ និង |

| ល.រ. | លក្ខខណ្ឌ | (★)<br>សាលារៀន ផ្កាយមួយ | (★★)<br>សាលារៀន ផ្កាយពីរ | (★★★)<br>សាលារៀន ផ្កាយបី |
|---|---|---|---|---|
| | | | | មានរបងការពារ ប្រសិនបើមានស្រះទឹក ឬអណ្តូងទឹកក្នុងបរិវេណសាលារៀន<br>• សាលារៀនអនុញ្ញាតតែចំណីអាហារដែលមានសុវត្ថិភាព និងសុខុមាលភាព។ |

## ផ្នែកទី ២ ៖ គោលការណ៍ណែនាំអនុវត្ត

ផ្នែកនេះ ពណ៌នាពីលក្ខណៈវិនិច្ឆ័យលើស្ថានភាពអនុវត្តរបស់សាលារៀនសម្រាប់កំណត់ចំណាត់ថ្នាក់សាលារៀនទៅតាមប្រភេទផ្កាយមួយ ផ្កាយពីរ និងផ្កាយបី។ ចំពោះសាលារៀន ដែលទទួលបានចំណាត់ថ្នាក់ផ្កាយមួយ គឺផ្ដើមចេញពីការបំពេញតាមលក្ខខណ្ឌអប្បបរមា ដែលសាលារៀនអាចអនុវត្តបាន ផ្អែកលើស្ថានភាពទឹកស្អាត និងអនាម័យដោយមិនពឹងផ្អែកជំនួយពីខាងក្រៅ។

សាលារៀននីមួយៗ អាចត្រូវការជំនួយបច្ចេកទេស និងធនធានមួយចំនួនសម្រាប់ទទួលបានចំណាត់ថ្នាក់ផ្កាយពីរ ឬផ្កាយបី ហើយជំនួយ និងធនធានទាំងនោះអាចទទួលបានពីនាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ អាជ្ញាធរមូលដ្ឋាន និងគណៈកម្មការទ្រទ្រង់សាលារៀនជាដើម។

ដើម្បីឱ្យសាលារៀនរក្សាបាននូវចំណាត់ថ្នាក់ផ្កាយណាមួយ ឬបង្កើននូវចំណាត់ថ្នាក់ផ្កាយលើសមុន ការសហការគ្នារវាងគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀនជាកត្តាដែលមិនអាចខ្វះបាន។ គណៈកម្មការទ្រទ្រង់សាលារៀនអាចជួយគណៈគ្រប់គ្រងសាលារៀន ក្នុងការរៀបចំផែនការអភិវឌ្ឍ ឬផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ដោយដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ខាងក្រោមនេះ ជាការកំណត់នូវលក្ខខណ្ឌអប្បបរមាទាំងបួន (៤) ប្រភេទ ដើម្បីទទួលបានចំណាត់ថ្នាក់ផ្កាយមួយ។

### ២.១. ទឹកស្អាតសម្រាប់ទទួលទាន

សិស្សទាំងអស់ត្រូវមានទឹកស្អាតសម្រាប់ទទួលទាននៅសាលារៀន។ ទឹកស្អាតសម្រាប់ទទួលទានអាចយកមកពីផ្ទះ ឬផ្ដល់ដោយសាលារៀន។

### តើអ្វីជាតម្រូវការសម្រាប់សាលារៀន ផ្កាយមួយ?

ភាគច្រើននៃសាលារៀន មិនទាន់មានលទ្ធភាពផ្ដល់ទឹកសម្រាប់ទទួលទានដល់សិស្សទាំងអស់គ្នាបានទេ ដូចនេះសិស្សម្នាក់ៗ ត្រូវយកទឹកសម្រាប់ទទួលទានពីផ្ទះរបស់ខ្លួន ឬពីប្រភពផ្សេងទៀត យ៉ាងហោចណាស់ ៥០០មីលីលីត្រ ក្នុងមួយវេនសិក្សា។ ទឹកយកពីផ្ទះ អាចជាទឹកដាំពុះ ឬទឹកចម្រោះ ឬទឹកដែលបានដាក់ក្លរីនរួច។ ដបដាក់ទឹកត្រូវសម្អាតជាប្រចាំ។

### តើអ្វីខ្លះដែលចាំបាច់ត្រូវធ្វើ?



- គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀនត្រូវពិភាក្សាគ្នាអំពីបញ្ហាទឹកស្អាតសម្រាប់ទទួលទាន និងជូនដំណឹងដល់អ្នកអាណាព្យាបាលសិស្សឱ្យយកទឹកស្អាតសម្រាប់ទទួលទានយ៉ាងហោចណាស់កន្លះលីត្រពីផ្ទះ ឬពីប្រភពផ្សេងទៀតពេលមកសាលារៀន។
- លោកគ្រូ អ្នកគ្រូ ត្រូវចូលរួម ៖
  - រំលឹកសិស្សពេលស្រង់វត្តមានពីការយកទឹកស្អាតសម្រាប់ទទួលទាន
  - ពិនិត្យស្ថានភាពដបដាក់ទឹកដែលសិស្សបានប្រើប្រាស់
  - ស្វែងរកមូលហេតុដែលសិស្សមិនបានយកទឹកសម្រាប់ទទួលទានមកសាលារៀន ដើម្បីរកដំណោះស្រាយ
  - ណែនាំសិស្សមិនឱ្យទទួលទានទឹកដបរួមគ្នា ឬប្តូរដបទឹកគ្នាទទួលទាននោះទេ ព្រោះសាលារៀនមិនមានលទ្ធភាពក្នុងការត្រួតពិនិត្យគុណភាពទឹកដែលសិស្សយកពីផ្ទះរៀងៗខ្លួននោះនៅឡើយ។
- គណៈគ្រប់គ្រងសាលារៀន ត្រូវពិភាក្សាគ្នាជាមួយគណៈកម្មការទ្រទ្រង់សាលារៀន លោកគ្រូ អ្នកគ្រូ ក្នុងការស្វែងរកលទ្ធភាពដាក់ធុងចម្រោះទឹកសម្រាប់ទទួលទាន នៅតាមថ្នាក់រៀន ដើម្បីដំឡើងចំណាត់ថ្នាក់សាលារៀនពីផ្កាយមួយ ទៅផ្កាយពីរ។

## ២.២. បង្គន់អនាម័យ និងបង្គន់នោម

ការបន្ទោបង់ក្រៅបង្គន់អនាម័យ គឺមានហានិភ័យខ្លាំងណាស់សម្រាប់សិស្ស និងសហគមន៍ទាំងមូល។ ហេតុនេះ សាលារៀនចាំបាច់ត្រូវមានបង្គន់អនាម័យ សម្រាប់សិស្សប្រើប្រាស់។

### តើអ្វីជាតម្រូវការសម្រាប់សាលារៀន ផ្ទាល់មួយ?

សាលារៀននីមួយៗ ត្រូវតែមានបង្គន់អនាម័យមួយសម្រាប់សិស្សស្រី និងមួយទៀតសម្រាប់សិស្សប្រុស។ បង្គន់អនាម័យ ត្រូវតែស្អាត ហើយសិស្សអាចប្រើប្រាស់បាននៅក្នុងម៉ោងសិក្សា។

### តើអ្វីខ្លះដែលចាំបាច់ត្រូវធ្វើ?



- គណៈគ្រប់គ្រងសាលារៀន ត្រូវធានាថា បង្គន់អនាម័យ ត្រូវមានទឹកសម្រាប់ប្រើប្រាស់ជាប្រចាំ
- បង្គន់អនាម័យត្រូវ៖
  - បានលាងសម្អាតជាប្រចាំថ្ងៃ
  - មានជាលក្ខណៈឯកជនសម្រាប់សិស្ស ដោយមានគន្លឹះពីក្នុង ហើយទ្វារអាចចាក់សោ។
- គណៈគ្រប់គ្រងសាលារៀន ត្រូវសហការជាមួយលោកគ្រូ អ្នកគ្រូ ដើម្បីបង្កើតវេនសម្អាតដល់សិស្ស និងតាមដានដំណើរការសម្អាតបង្គន់អនាម័យជាប្រចាំ
- ករណីដែលសាលារៀនមិនមានបង្គន់អនាម័យ ឬបង្គន់អនាម័យត្រូវខូចខាតមិនអាចជួសជុលបានឬមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សម្ភារៈសម្រាប់ធ្វើអនាម័យ គណៈគ្រប់គ្រងសាលារៀនត្រូវដាក់សំណើទៅកាន់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ឬអាជ្ញាធរមូលដ្ឋាន ដើម្បីសុំជំនួយគាំទ្រ។គណៈគ្រប់គ្រងសាលារៀនអាចធ្វើការដោយផ្ទាល់ជាមួយគណៈកម្មការទ្រទ្រង់សាលារៀន សហគមន៍ រួមទាំងអ្នកដឹកនាំសាសនា ដើម្បីសុំការគាំទ្រ។

## ២.៣. បរិក្ខារលាងសម្អាតដៃ

ការលាងសម្អាតដៃ នឹងសាប៊ូគឺជាវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការបង្ការជំងឺពិសេសជំងឺរាក និងជំងឺផ្លូវដង្ហើម។ ការលាងសម្អាតដៃជាប្រចាំបង្កើតទម្លាប់ដល់សិស្ស និងបង្កើតនូវបរិយាកាសប្រកបដោយសុខុមាលភាព។

## តើអ្វីជាតម្រូវការសម្រាប់សាលារៀន ផ្តាយមួយ?




សាលារៀនត្រូវមានបរិក្ខារលាងសម្អាតដៃ។ បរិក្ខារលាងសម្អាតដៃត្រូវនៅជិតបង្គន់អនាម័យ ឬជិតបន្ទប់រៀន ហើយត្រូវមានទឹក និងសាប៊ូ គ្រប់ពេលវេលាទាំងអស់។

### តើអ្វីខ្លះដែលចាំបាច់ត្រូវធ្វើ?

- ត្រូវមានទឹក និងសាប៊ូសម្រាប់ប្រើប្រាស់ក្នុងការលាងសម្អាតដៃ
- តម្លៃទឹក និងសាប៊ូអាចដាក់បញ្ចូលនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់សាលារៀន ហើយសាលារៀនអាចរកថវិកាបន្ថែមពីសហគមន៍ ឬពីប្រភពផ្សេងៗទៀត
- ត្រូវឱ្យសិស្សអនុវត្តការលាងសម្អាតដៃ ពិសេសបន្ទាប់ពីប្រើប្រាស់បង្គន់អនាម័យ និងមុនពេលបរិភោគចំណីអាហារ ដើម្បីឱ្យក្លាយជាទម្លាប់ល្អសម្រាប់ជីវិត
- មិនគួរប្រើប្រាស់កន្សែងជូតដៃទេ ព្រោះការប្រើប្រាស់កន្សែងសម្រាប់ជូតដៃរួមគ្នាគឺជាប្រភពចម្លងមេរោគ។

## ២.៤. បរិស្ថាន និងសុវត្ថិភាព

សាលារៀនមានត្រូវមានបរិស្ថានស្អាត និងមានសុវត្ថិភាព ដែលជាទីកន្លែងមេត្រីភាព សម្រាប់បុគ្គលិកអប់រំ និងអ្នកសិក្សា ក្នុងការបង្រៀន និងរៀនបានពេញលេញ។ ការរៀបចំសាលារៀនឱ្យមានបរិស្ថានស្អាត និងមានសុវត្ថិភាព ជាទំនួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ជុំវិញសាលារៀន។

### តើអ្វីជាតម្រូវការសម្រាប់សាលារៀន ផ្កាយមួយ?



- សាលារៀនមិនមានសំរាម នៅក្នុងបរិវេណសាលារៀន និងនៅតាមបន្ទប់រៀន
- សាលារៀនត្រូវមានធុងទុកដាក់សំរាមយ៉ាងហោចណាស់មួយ
- សិស្សត្រូវបានអនុញ្ញាតឱ្យបរិភោគតែចំណីអាហារដែលមានសុវត្ថិភាព និងមានសុខុមាលភាពនៅក្នុងសាលារៀន ទោះជាអាហារដែលពួកគេយកពីផ្ទះ ឬផ្តល់ដោយសាលារៀន ឬទិញពីអ្នកលក់នៅសាលារៀន។

### តើអ្វីខ្លះដែលចាំបាច់ត្រូវធ្វើ?

- គណៈគ្រប់គ្រងសាលារៀនត្រូវធានាថា សាលារៀនមានធុងសំរាម ហើយបានប្រើប្រាស់ និងគ្មានសំរាមនៅក្នុងបរិវេណសាលារៀន និងបន្ទប់រៀន
- គណៈគ្រប់គ្រងសាលារៀន ត្រូវសហការជាមួយលោកគ្រូ អ្នកគ្រូ ដើម្បីបង្កើតវេនសម្អាតដល់សិស្ស និងតាមដានដំណើរការសម្អាតបរិវេណសាលារៀន បន្ទប់រៀន បង្គន់អនាម័យ និងបរិក្ខារលាងសម្អាតដៃបង្គន់អនាម័យជាប្រចាំ
- គ្រូទទួលបន្ទុកការងារសុខភាពសិក្សា ឬការងារទឹកស្អាត និងអនាម័យ នៅតាមសាលារៀន ត្រូវធ្វើការជាមួយប្រធានថ្នាក់ ក្នុងការផ្តើមយុទ្ធនាការធ្វើឱ្យសាលារៀនមានបរិស្ថានស្អាត និងមានសុវត្ថិភាព ដូចជាការដាក់ស្លាកសញ្ញាថា ត្រូវដាក់សំរាមក្នុងធុងសំរាម ដើម្បីលើកទឹកចិត្តឱ្យមានការទម្លាប់ល្អ។

## ផ្នែកទី៣ ៖ គោលការណ៍វាយតម្លៃ

### ៣.១. ការពិនិត្យតាមដាន

ការពិនិត្យតាមដានជាកត្តាមិនអាចខ្វះបាន ដើម្បីធានាថាសាលារៀន បានអនុវត្តយ៉ាងខ្ជាប់ខ្ជួនស្របតាមលក្ខណ្ឌនានានៃលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យ និងដើម្បីប៉ាន់ប្រមាណពីតម្រូវការសម្រាប់អភិវឌ្ឍន៍សាលារៀន។

គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ចាំបាច់ត្រូវធ្វើការពិនិត្យតាមដានឱ្យបានទៀងទាត់ ក្នុងការអនុវត្តលក្ខខណ្ឌអប្បបរមានេះ។ គ្រូទទួលបន្ទុកសុខភាពសិក្សានៅតាមសាលារៀន ត្រូវធ្វើការងារនេះជាប្រចាំ និងត្រូវលើកសំណើដោះស្រាយនូវបញ្ហាសំខាន់ៗមួយចំនួនដូចជា ការស្នើសុំការថែរក្សា និងការជួសជុលសម្ភារបរិក្ខារទឹកស្អាត និងអនាម័យជាដើម។

គ្រូទទួលបន្ទុកសុខភាពសិក្សា នៅតាមសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ត្រូវលើកយកបញ្ហាដែលបានរកឃើញពីការពិនិត្យតាមដានទៅពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំខែរបស់សាលារៀន។

ការពិនិត្យតាមដាន អាចធ្វើរួមគ្នារវាងមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ព្រមទាំងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ ក្រុង ស្រុក នៅតាមសាលារៀន។ លទ្ធផលនៃការពិនិត្យតាមដាន នឹងត្រូវលើកជាអនុសាសន៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពទឹកស្អាត និងអនាម័យតាមសាលារៀនសម្រាប់ឆ្នាំសិក្សាបន្ទាប់ផងដែរ។

## ៣.២. ការវាយតម្លៃសាលារៀន ចំណាត់ថ្នាក់ "ផ្កាយ"

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ក្នុងការវាយតម្លៃចំណាត់ថ្នាក់ ផ្កាយ របស់សាលារៀន មួយឆ្នាំសិក្សាម្តង។

ឧបករណ៍សម្រាប់ពិនិត្យតាមដាន និងវាយតម្លៃពីស្ថានភាពទឹកស្អាត និងអនាម័យនៅតាមសាលារៀន មាននៅក្នុង "តារាងទី១" រីឯការធ្វើចំណាត់ថ្នាក់ "ផ្កាយ" របស់សាលារៀនមាននៅក្នុង "តារាងទី២"។

ក្រោយពីបានឯកភាពលើលទ្ធផលនៃចំណាត់ថ្នាក់ "ផ្កាយ" របស់សាលារៀនរួចតាមរយៈក្រុមការងារវាយតម្លៃ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវស្នើសុំលិខិតបញ្ជាក់ពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត។

ការវាយតម្លៃអាចប្រព្រឹត្តទៅមុនពេល ឬតំណាលគ្នានៃការបំពេញកម្រងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) របស់សាលារៀន។

មន្ទីរអប់រំ យុវជន និងកីឡា សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ក្នុងការប្រគល់ជូននូវវិញ្ញាបនបត្របញ្ជាក់ចំណាត់ថ្នាក់ "ផ្កាយ" របស់សាលារៀន នាឱកាសសមស្របណាមួយ ដល់សាលារៀនទាំងនោះ ក្នុងពេលប្រារព្ធពិធីផ្សេងៗដូចជា ពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មីជាដើម។

## តារាងទី១ ៖ គម្រូទសំណួរសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ

### ក. ព័ត៌មានទូទៅ

| | |
|---|---|
| ឈ្មោះសាលារៀន ៖ | |
| លេខកូដសាលារៀន ៖ | |
| ឈ្មោះភូមិ ៖ | |
| ឈ្មោះឃុំ/សង្កាត់ ៖ | |
| ឈ្មោះខណ្ឌ/ក្រុង/ស្រុក ៖ | |
| ឈ្មោះរាជធានី/ខេត្ត ៖ | |
| កាលបរិច្ឆេទ ៖ | |
| ឈ្មោះនាយកសាលារៀន ៖ | |
| លេខទូរស័ព្ទនាយកសាលារៀន ៖ | |
| ឈ្មោះអ្នកចុះពិនិត្យតាមដាន ៖ | |
| លេខទូរស័ព្ទ អ្នកចុះពិនិត្យតាមដាន ៖ | |

### ខ. ព័ត៌មានពាក់ព័ន្ធទឹកស្អាត និងអនាម័យ

| ល.រ | ១. ទឹកស្អាតសម្រាប់ទទួលទាន | បាទ/ចាស | ទេ |
|---|---|---|---|
| ១.០ | សិស្សទាំងអស់ត្រូវមានទឹកស្អាតសម្រាប់ទទួលទាននៅសាលារៀន | | |
| ១.១ | សិស្សទាំងអស់ត្រូវមានទឹកស្អាតសម្រាប់ទទួលទានយ៉ាងតិច ៥០០ មីលីលីត្រ ក្នុងមួយវេនសិក្សា ដោយយកពីផ្ទះ ឬពីប្រភពផ្សេងទៀត | | |
| ១.២ | ទឹកស្អាតសម្រាប់ទទួលទានផ្តល់ដោយសាលារៀន ប៉ុន្តែការផ្គត់ផ្គង់មិនទាន់មានភាពទៀងទាត់ ហើយសិស្សចាំបាច់យកទឹកស្អាតពីប្រភពផ្សេងៗទៀត ដូចជាយកពីផ្ទះ ឬពីប្រភពផ្សេងទៀត | | |
| ១.៣ | សាលារៀនមានផ្តល់ទឹកស្អាតសម្រាប់ទទួលទានដល់សិស្សទាំងអស់នៅគ្រប់វេនសិក្សា | | |
| **ចំណាំ ៖**<br>១) ប្រសិនបើចម្លើយ ១.០ ទេ សូមរំលង ១.១ ១.២ ១.៣<br>២) ប្រសិនបើចម្លើយ ១.០ បាទ/ចាស សូមបន្ត ១.១ ១.២ ១.៣<br>៣) វាយតម្លៃ និងចំណាត់ថ្នាក់ផ្កាយមានដូចខាងក្រោម ៖<br>★ = ១.០ បាទ/ចាសបូក ១.១ បាទ/ចាស<br>★★ = ១.០ បាទ/ចាសបូក ១.២ បាទ/ចាស<br>★★★ = ១.០ បាទ/ចាស បូក ១.៣ បាទ/ចាស | | ចំណាត់ថ្នាក់ផ្កាយ | |

| ល.រ | ២. បង្គន់អនាម័យ និងបង្គន់នោម | បាទ/ចាស | ទេ |
|---|---|---|---|
| ២.០ | បង្គន់អនាម័យនៅសាលារៀនត្រូវតែប្រើប្រាស់បាន | | |
| ២.១ | សាលារៀនមានបង្គន់អនាម័យយ៉ាងតិចមួយសម្រាប់សិស្សប្រុស និងមួយសម្រាប់សិស្សស្រី | | |
| ២.២ | សាលារៀនមានបង្គន់អនាម័យលើសពីមួយសម្រាប់សិស្សប្រុស និងលើសពីមួយសម្រាប់សិស្សស្រី | | |
| ២.៣ | សាលារៀនមានបង្គន់អនាម័យយ៉ាងតិចមួយដែលកុមារពិការកាយសម្បទាអាចប្រើប្រាស់បាន ឬយ៉ាងហោចណាស់បង្គន់ត្រូវមានជម្រាលសម្រាប់ឡើង | | |
| ២.៤ | សាលារៀនមានបង្គន់អនាម័យដែលបំពេញតាមស្តង់ដារជាតិ គឺមានបង្គន់អនាម័យ២ និងបង្គន់នោម៣ សម្រាប់សិស្សប្រុស១០០នាក់ និងបង្គន់អនាម័យ៣ សម្រាប់សិស្សស្រី១០០នាក់ | | |
| ២.៥ | សាលារៀនមានទឹកសម្រាប់ធ្វើការលាងសម្អាត ដែលយកមកពីប្រភពទឹកដែលបានកែលម្អ | | |
| ២.៦ | សាលារៀនមានសំឡីអនាម័យសម្រាប់សិស្សស្រី ប្រើប្រាស់ពេលត្រូវការបន្ទាន់ | | |
| ២.៧ | បង្គន់អនាម័យសិស្សស្រី មានធុងសំរាម សម្រាប់គ្រប់គ្រងអនាម័យពេលមករដូវ | | |
| **ចំណាំ ៖**<br>១) ប្រសិនបើចម្លើយ ២.០ ទេ សូមរំលង ២.១ ២.២ ២.៣ ២.៤ ២.៥ ២.៦ ២.៧<br>២) ប្រសិនបើចម្លើយ ២.០ បាទ/ចាស សូមបន្ត ២.១ ២.២ ២.៣ ២.៤ ២.៥ ២.៦ ២.៧<br>៣) វាយតម្លៃ និងចំណាត់ថ្នាក់ផ្កាយមានដូចខាងក្រោម ៖<br>★ = ២.០ បាទ/ចាសបូក ២.១ បាទ/ចាស<br>★★ = ២.០ បាទ/ចាសបូក ២.២ និង ២.៣ បាទ/ចាស<br>★★★ = ២.០ បាទ/ចាសបូក ២.៤ ២.៥ ២.៦ និង ២.៧ បាទ/ចាស | | ចំណាត់ថ្នាក់ផ្កាយ | |

| ល.រ | **៣. បរិក្ខារលាងសម្អាតដៃ** | **បាទ/ចាស** | **ទេ** |
|---|---|---|---|
| ៣.០ | រាល់បរិក្ខារលាងសម្អាតដៃត្រូវតែមានទឹក និងសាប៊ូនៅគ្រប់ពេលវេលា | | |
| ៣.១ | សាលារៀនមានបរិក្ខារលាងសម្អាតដៃនៅជិតបង្គន់អនាម័យ ឬនៅជិតបន្ទប់រៀន | | |
| ៣.២ | សាលារៀនមានបរិក្ខារលាងសម្អាតដៃជាក្រុមយ៉ាងតិចមួយ | | |
| ៣.៣ | សាលារៀនមានកាលវិភាគសម្រាប់ការលាងសម្អាតដៃជាក្រុមប្រចាំថ្ងៃ | | |
| ៣.៤ | បរិក្ខារលាងសម្អាតដៃជាច្រើនទៀត អាចប្រើប្រាស់សម្រាប់សកម្មភាពលាងសម្អាតដៃប្រចាំថ្ងៃ | | |
| ៣.៥ | សិស្សគ្រប់រូបចូលរួមនៅក្នុងការសកម្មភាពលាងសម្អាតដៃ ជាក្រុមជារៀងរាល់ថ្ងៃ (*សម្រាប់តែបឋម និងមត្តេយ្យសិក្សា*) | | |
| ៣.៦ | សិស្សគ្រប់រូបចូលរួមដុសសម្អាតធ្មេញជារៀងរាល់ថ្ងៃ<br>(*សម្រាប់តែបឋម និងមត្តេយ្យសិក្សា*) | | |
| ៣.៧ | ទឹកប្រើប្រាស់ត្រូវយកពីប្រភពទឹកដែលបានកែលម្អ | | |
| **ចំណាំ ៖**<br>១) ប្រសិនបើចម្លើយ ៣.០ ទេ សូមរំលង ៣.១ ៣.២ ៣.៣ ៣.៤ ៣.៥ ៣.៦ ៣.៧<br>២) ប្រសិនបើចម្លើយ ៣.០ បាទ/ចាស សូមបន្ត ៣.១ ៣.២ ៣.៣ ៣.៤ ៣.៥ ៣.៦ ៣.៧<br>៣) វាយតម្លៃ និងចំណាត់ថ្នាក់ផ្កាយមានដូចខាងក្រោម ៖<br>★ = ៣.០ បាទ/ចាសបូក ៣.១ បាទ/ចាស<br>★★ = ៣.០ បាទ/ចាសបូក ៣.២ និង ៣.៣ បាទ/ចាស<br>★★★ = ៣.០ បាទ/ចាសបូក ៣.៤ ៣.៥ ៣.៦ និង ៣.៧ បាទ/ចាស | | ចំណាត់ថ្នាក់ផ្កាយ | |

| ល.រ | **៩. បរិស្ថាន និងសុវត្ថិភាព** | បាទ/ចាស | ទេ |
|---|---|---|---|
| ៩.០ | សាលារៀនមានវេនសម្អាតទីធ្លា បន្ទប់រៀន និងបង្គន់អនាម័យ ហើយគ្មានសំរាមក្នុងទីធ្លា និងក្នុងបន្ទប់រៀន | | |
| ៩.១ | សាលារៀនមានធុងសំរាមយ៉ាងតិចមួយសម្រាប់ដាក់សំរាម ដែលបានប្រមូល | | |
| ៩.២ | សាលារៀនមានធុងសំរាម យ៉ាងតិច២ ប្រភេទ គឺធុងសំរាមសម្រាប់ដាក់ ***សំណល់ សរីរាង្គ*** និងធុងសំរាមសម្រាប់ ដាក់ ***សំណល់ផ្សេងៗ*** | | |
| ៩.៣ | សាលារៀនមានធុងសំរាម ៣ ប្រភេទ គឺធុងសំរាមសម្រាប់ដាក់ ***សំណល់សរីរាង្គ*** ធុងសំរាមសម្រាប់ដាក់ ***សំណល់ផ្សេងៗ*** និងធុងសំរាម សម្រាប់ដាក់ ***សំណល់កែច្នៃ*** | | |
| ៩.៤ | សាលារៀនមានរបងព័ទ្ធជុំវិញ និងមានរបងការពារប្រសិនបើមានទឹកស្រះទឹក ឬអណ្តូងទឹកក្នុងបរិវេណសាលារៀន | | |
| ៩.៥ | សាលារៀនអនុញ្ញាតតែចំណីអាហារដែលមានសុវត្ថិភាព និង សុខុមាលភាព | | |
| **ចំណាំ ៖**<br>១) ប្រសិនបើចម្លើយ ៩.០ ទេ សូមរំលង ៩.១ ៩.២ ៩.៣ ៩.៤ ៩.៥<br>២) ប្រសិនបើចម្លើយ ៩.០ បាទ/ចាស សូមបន្ត ៩.១ ៩.២ ៩.៣ ៩.៤ ៩.៥<br>៣) វាយតម្លៃ និងចំណាត់ថ្នាក់ផ្កាយមានដូចខាងក្រោម ៖<br>★ = ៩.០ បាទ/ចាសបូក ៩.១ បាទ/ចាស<br>★★ = ៩.០ បាទ/ចាសបូក ៩.២ បាទ/ចាស<br>★★★ = ៩.០ បាទ/ចាសបូក ៩.៣ ៩.៤ និង៩.៥ បាទ/ចាស | | ចំណាត់ថ្នាក់ផ្កាយ | |

## តារាងទី២ ៖ ការបូកសរុបវាយតម្លៃចំណាត់ថ្នាក់សាលារៀន

| សមាសធាតុ | គណៈគ្រប់គ្រងសាលារៀន | តំណាងការិយាល័យ អប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ | តំណាង មន្ទីរអប់រំ យុវជន និង កីឡា រាជធានី ខេត្ត | តំណាងថ្នាក់ជាតិ |
|---|---|---|---|---|
| ឈ្មោះ | | | | |
| តួនាទី | | | | |
| ហត្ថលេខា | | | | |
| កាលបរិច្ឆេទ | | | | |

| លរ | លក្ខខណ្ឌអប្បបរមានៃទឹកស្អាត និងអនាម័យ | ចំណាត់ថ្នាក់ផ្កាយ (តារាងទី១) |
|---|---|---|
| ១ | ទឹកស្អាតសម្រាប់ទទួលទាន | |
| ២ | បង្គន់អនាម័យ និងបង្គន់នោម | |
| ៣ | បរិក្ខារលាងសម្អាតដៃ | |
| ៤ | បរិស្ថាន និងសុវត្ថិភាព | |
| ចំនួនផ្កាយសរុបគ្រប់លក្ខខណ្ឌ (0 ដល់១២) | | |
| **ចំណាត់ថ្នាក់ "ផ្កាយ" របស់សាលារៀន**<br>បើផ្កាយសរុប ៤-៦ = ★; ៧-១០ = ★★; ១១-១២ = ★★★<br>ក្នុងករណីលក្ខខណ្ឌទី២ គ្មាន "★" បានន័យថាសាលារៀននោះ គ្មានជាប់ចំណាត់ថ្នាក់ "★" នោះទេ។ | | |

### ៣.៣. ភារកិច្ច និងការទទួលខុសត្រូវ

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបពីទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការអនុវត្តគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យ ៖

#### ក. ក្រុមការងារថ្នាក់ជាតិ ស្តីពីទឹកស្អាត និងអនាម័យ

- សម្របសម្រួល និងគាំទ្រដំណើរការកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀន
- សហការជាមួយក្រុមការងារអន្តរក្រសួង និងដៃគូអភិវឌ្ឍន៍នានា ក្នុងការអភិវឌ្ឍកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀន
- ធ្វើការតស៊ូមតិក្នុងការបញ្ចូលការអភិវឌ្ឍកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀនទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ពិសេសផែនការថវិកាជាតិ
- កៀរគរប្រភពធនធាន សម្រាប់ការអនុវត្ត និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពទឹកស្អាត និងអនាម័យ នៅតាមសាលារៀន
- រាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀន ដល់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា។

#### ខ. មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត

- តម្រង់ទិស ឬបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងតំណាងគណៈកម្មការទ្រទ្រង់សាលារៀនពីគោលការណ៍ណែនាំ អនុវត្តស្តីពីទឹកស្អាត និងអនាម័យ នៅតាមសាលារៀន
- ចូលរួមពិនិត្យតាមដានជាមួយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់ផ្កាយរបស់សាលារៀន
- ចេញលិខិតបញ្ជាក់លក្ខណៈវិនិច្ឆ័យសាលារៀនដែលទទួលបាន "ផ្កាយ"
- ផ្ទៀងផ្ទាត់ និងត្រួតពិនិត្យសាលារៀនដែលទទួលបានចំណាត់ថ្នាក់ផ្កាយ និងផ្តល់អនុសាសន៍ ដើម្បីឱ្យសាលារៀនឈានឡើងទៅផ្កាយបន្ទាប់
- រាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀនជូនក្រសួងអប់រំ យុវជននិងកីឡា (នាយកដ្ឋានសុខភាពសិក្សា)។

## គ. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ

- តម្រង់ទិស ឬបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ និងតំណាងគណៈកម្មការទ្រទ្រង់សាលារៀនពីគោលការណ៍ណែនាំ អនុវត្តស្តីពីទឹកស្អាត និងអនាម័យ នៅតាមសាលារៀន
- ចូលរួមពិនិត្យតាមដានជាមួយគណៈគ្រប់គ្រងសាលារៀន និងគណៈកម្មការទ្រទ្រង់សាលារៀន ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់ផ្កាយរបស់សាលារៀន
- ផ្ទៀងផ្ទាត់ និងត្រួតពិនិត្យសាលារៀនដែលទទួលបានចំណាត់ថ្នាក់ផ្កាយ និងផ្តល់អនុសាសន៍ ដើម្បីឱ្យសាលារៀនឈានឡើងទៅផ្កាយបន្ទាប់
- រាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀនតាមក្រុង ស្រុក ខណ្ឌនីមួយៗ ទៅគណៈកម្មការសុខភាពសិក្សានៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

## ឃ. គណៈគ្រប់គ្រងសាលារៀន

- ជំរុញលើកទឹកចិត្តដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងការអនុវត្តសកម្មភាពនានា ដើម្បីបំពេញបាននូវលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យ នៅតាមសាលារៀន ពិសេសរក្សានូវចំណាត់ថ្នាក់ផ្កាយ ឬបង្កើនចំណាត់ថ្នាក់ផ្កាយ
- អភិវឌ្ឍផែនការសកម្មភាព ដើម្បីធ្វើឱ្យស្ថានភាពទឹកស្អាត និងអនាម័យ នៅតាមសាលារៀនមានភាពប្រសើរឡើង
- ចលនាប្រភពធនធាន ជាមួយគណៈទ្រទ្រង់សាលារៀន តំណាងមាតាបិតាសិស្ស និងវិស័យឯកជនក្នុងការអភិវឌ្ឍកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀនឱ្យមានភាពរីកចម្រើន។

## ង. គ្រូទទួលបន្ទុកសុខភាពសិក្សា

- ចូលរួមវគ្គបណ្តុះបណ្តាល វគ្គបំប៉ន សិក្ខាសាលា ស្តីពីទឹកស្អាត និងអនាម័យ ដើម្បីយកចំណេះដឹងទៅអនុវត្ត ឱ្យក្លាយជាទម្លាប់សម្រាប់ជាគំរូដល់សិស្ស
- ណែនាំដល់សិស្សឱ្យអនុវត្តវិធានការអនាម័យ និងតាមដានការអនុវត្តរបស់សិស្ស ព្រមទាំងដឹកនាំការថែរក្សាបរិក្ខារទឹកស្អាត និងអនាម័យនៅតាមសាលារៀនជាប្រចាំ

- រាយការណ៍ពីស្ថានភាពទឹកស្អាត និងអនាម័យដល់គណៈគ្រប់គ្រងសាលារៀន ពិសេសការស្នើជួសជុលបន្ទាន់នានា។

### ច. ក្រុមប្រឹក្សាយុវជន ឬក្រុមប្រឹក្សាកុមារ

- ចូលរួមអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀន តាមការណែនាំ របស់លោកគ្រូ អ្នកគ្រូ
- លើកទឹកចិត្តមិត្តរួមថ្នាក់ឱ្យចេះប្រើប្រាស់សម្ភារបរិក្ខាទឹកស្អាត និងអនាម័យ ឱ្យបានត្រឹមត្រូវ និងប្រកបដោយការទទួលខុសត្រូវ ពិសេសការប្រកាន់ខ្ជាប់នូវឥរិយាបថជាវិជ្ជមានរៀងរាល់ថ្ងៃ
- ចូលរួមផ្តល់យោបល់ក្នុងការរៀបចំសាងសង់ និងសម្អាតសម្ភារបរិក្ខាទឹកស្អាត និងអនាម័យ។

### ឆ. គណៈកម្មការទ្រទ្រង់សាលារៀន និងមាតាបិតាសិស្ស

- សហការអភិវឌ្ឍសាលារៀន និងចូលរួមពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការ
- សហការជាមួយគណៈគ្រប់គ្រងសាលារៀន ក្នុងការដាក់បញ្ចូលផ្នែកនានានៃផែនការអភិវឌ្ឍសាលារៀនទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់
- ចូលរួមកសាងសមត្ថភាពដែលបានរៀបចំឡើង ដើម្បីផ្តល់ការគាំទ្រដល់ការកសាងផែនការ ការអនុវត្តកម្មវិធី និងការពិនិត្យតាមដាន
- សហការជាមួយបុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការវាយតម្លៃពីចំណាត់ថ្នាក់ផ្កាយ និងផ្តល់អនុសាសន៍ ដើម្បីឱ្យសាលារៀនឈានឡើងទៅផ្កាយបន្ទាប់
- គាំទ្រដល់សាលារៀន ក្នុងការរក្សាបាននូវចំណាត់ថ្នាក់ផ្កាយរបស់ខ្លួន និងពង្រឹងខ្លួន ដើម្បីទទួលបានចំណាត់ថ្នាក់ផ្កាយខ្ពស់ជាងមុន
- ចូលរួមជាមួយសាលារៀន ក្នុងការថែរក្សាការពារសម្ភារបរិក្ខាទឹកស្អាត និងអនាម័យ
- កៀរគរសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ឱ្យចូលរួមជាថវិកា កម្លាំងពលកម្ម និងសម្ភារៈ ក្នុងការធានាដល់ការកែលម្អស្ថានភាពទឹកស្អាត និងអនាម័យនៅតាមសាលារៀន
- ចូលរួមណែនាំ និងរំឭកកូនចៅរបស់ខ្លួន ឱ្យអនុវត្តវិធានការអនាម័យជាប់ជាប្រចាំក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# គោលនយោបាយ

# ស្តីពី

# សុខភាពសិក្សា

# មាតិកា


| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| អារម្ភកថា | |
| I -សេចក្តីផ្តើម | ០១ |
| II -គោលបំណង | ០២ |
| III -គោលនយោបាយ | ០២ |
| គោលនយោបាយទី ១ | ០៣ |
| គោលនយោបាយទី ២ | ០៤ |
| គោលនយោបាយទី ៣ | ០៦ |
| គោលនយោបាយទី ៤ | ០៧ |
| IV -អវសានកថា | ០៨ |


ꩠꩠ꧁ꩡꩡ

# អារម្ភកថា

គោលនយោបាយសុខភាពសិក្សានឹងផ្តល់វិភាគទានយ៉ាងសំខាន់ សម្រាប់លើកកំពស់គុណភាពអប់រំ និង ការកាត់បន្ថយអត្រាឆ្លងជំងឺផ្សេងៗរួមទាំងជំងឺអេដស៍ផងដែរ ដើម្បីឆ្លើយតបទៅនឹង**ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា** ដោយធានាឱ្យមានយុត្តិធម៌ សមធម៌សង្គម និង សិទ្ធិកុមារ ព្រមទាំងផ្តល់វិភាគទានផ្ទាល់ដល់កិច្ចការខិតខំប្រឹងប្រែងដ៏ធំធេងរបស់ប្រទេសជាតិក្នុងការលុបបំបាត់ភាពក្រីក្រ ។

គោលនយោបាយសុខភាពសិក្សា ត្រូវបានរៀបចំឡើងដោយមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធទាំងអស់រួមមាន ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល ក្នុងបរិបទសាលាកុមារមេត្រី ។

គោលនយោបាយសុខភាពសិក្សាមានគោលបំណងរួមចំណែកលើកកំពស់គុណភាពអប់រំតាមរយៈការណែនាំ សិស្ស និស្សិតឱ្យមានទំលាប់រស់នៅស្អាត រួមចំណែកធ្វើឱ្យបរិស្ថានសាលារៀនមានអនាម័យប្រកបដោយសុវត្ថិភាព និង ផ្តល់សិទ្ធិស្មើគ្នាក្នុងការទទួលសេវាថែទាំសុខភាព ចំពោះសិស្សានុសិស្ស និស្សិត បុគ្គលិកសិក្សាគ្រប់រូប ដោយផ្អែកទៅលើផែនការដ៏ប្រសើរមួយសម្រាប់សកម្មភាពត្រួតពិនិត្យសុក្កានុពលសុខភាព ។

ដើម្បីឱ្យប្រទេសជាតិរីកចំរើន ប្រទេសទាំងអស់នៅលើពិភពលោកត្រូវតែធានាឱ្យប្រជាពលរដ្ឋគ្រប់ៗរូបមានសុខភាព និង សុខុមាលភាពពេញលេញ។ ការលើកកំពស់សុខភាពតាមសាលារៀន គឺជាសមាសភាគមួយមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍធនធានមនុស្សឱ្យមានគុណភាព ដើម្បីឆ្លើយតបទៅនឹងការរីកចំរើនផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ចដែលពិភពលោកទាំងមូលកំពុងតែបោះជំហានយ៉ាងលឿនក្នុងចរន្តសកលភាវូបនីយកម្ម និង តំបន់ភាវូនីយកម្ម ។

វិសាលភាពនៃគោលនយោបាយនេះផ្តល់ជាយុទ្ធសាស្ត្រ វិធីសាស្ត្រ គំរោង និង ការណែនាំសម្រាប់សកម្មភាពអនុវត្តជាក់ស្តែងលើការអប់រំផ្សព្វផ្សាយស្តីពីវិធានការបង្ការជំងឺឆ្លងផ្សេង ៗ តាមគោលវិធីសិស្សមជ្ឈមណ្ឌល ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា **គោលនយោបាយសុខភាពសិក្សា** នេះនឹងទទួលបាននូវការគាំទ្រ និង ចូលរួមយ៉ាងសកម្មនៅក្នុងការណែនាំ អនុវត្តន៍ ពិនិត្យ និងវាយតម្លៃសកម្មភាពនៅតាមសាលារៀន គ្រឹះស្ថានសិក្សាទាំងសាធារណៈ និងឯកជន គ្រួសារ សហគមន៍ និងសង្គមទាំងមូល ។

## I. សេចក្តីផ្តើម ៖

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ពិភពលោកទាំងមូលមានការប្រែប្រួលយ៉ាងខ្លាំង ទាំងសេដ្ឋកិច្ចសង្គម វប្បធម៌ និង នយោបាយ ។ នេះដោយសារតែមានការរីកចំរើនផ្នែកឧស្សាហកម្ម កំណើនប្រជាជននៅតាមទីក្រុង ការផ្លាស់ប្តូរបរិស្ថាន បម្រែបម្រួលការរស់នៅ ទំនើបភាវូបនីយកម្មទីផ្សារ និង សកលភាវូបនីយកម្មសេដ្ឋកិច្ច។ រាល់បម្រែបម្រួលទាំងនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពសាធារណៈ ពិសេសមនុស្ស និង សត្វ។ ដូចនេះការលើកកំពស់សុខភាព គឺជាគោលដៅយុទ្ធសាស្ត្រមួយសំដៅជំរុញឱ្យបុគ្គល និង សហគមន៍មានឥរិយាបថល្អ និង បំណិនសមស្រប ដើម្បីបង្ការជំងឺផ្សេងៗ និង លើកកំពស់តំលៃសុខភាពថែមទៀត ។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកក្រសួងអប់រំ យុវជន និង កីឡា ជាក្រសួងអាទិភាពមួយក្នុងការអភិវឌ្ឍធនធានមនុស្ស ក្នុងនោះមានទាំងជំនាន់កុមារ និង យុវវ័យ ដែលជាមុខសញ្ញាអាទិភាពនៃការអប់រំ និង បណ្តុះបណ្តាលក្នុងបុព្វហេតុប្រទេសជាតិ ។

គោលដៅនៃការអប់រំ គឺបណ្តុះបណ្តាលពលរដ្ឋកម្ពុជាឱ្យមានការរីកចំរើនគ្រប់ផ្នែក ទាំងបញ្ញា ស្មារតី កាយសម្បទា និង សីលសម្បទា មានបទពិសោធខាងបច្ចេកទេសវិជ្ជាជីវៈ មានស្មារតីស្នេហាជាតិ និង ស្មារតីទទួលខុសត្រូវជាពលរដ្ឋល្អ ដើម្បីរួមចំណែកការពារ កសាង និង អភិវឌ្ឍប្រទេសជាតិ ។

សុខភាពជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ។ សុខភាពជាសភាពមានសុខុមាលភាពពេញលេញផ្នែកកាយសម្បទា ផ្លូវចិត្ត និងផ្នែកសង្គម មិនមែនគ្រាន់តែជាភាពគ្មានជំងឺ ឬមិនពិការឡើយ ។ សុខភាពជាទ្រព្យដ៏គាប់ប្រសើរបំផុតសម្រាប់យើង។ ការយកចិត្តទុកដាក់លើសុខភាពមានន័យថា យើងបានយកចិត្តទុកដាក់រាល់ការងារ ដែលយើងកំពុងធ្វើ ។ ការទំលាប់ធ្វើឱ្យមានសុខភាពល្អ ពិតជាអាចធ្វើឱ្យជីវិតយើងកាន់តែប្រសើរឡើង និង មានសុភមង្គល ។

បច្ចុប្បន្ននេះ ការលើកកំពស់សុខភាពនៅតាមសាលារៀន បាននិងកំពុងអនុវត្តជាបណ្តើរៗ នៅតាមខេត្តក្រុង និងសាលារៀនមួយចំនួន ជាពិសេសក្នុងតំបន់ដែលជួបប្រទះបញ្ហាសុខភាពច្រើនជាងគេ។ សាលារៀនទាំងនោះបានទទួលនូវសេវាផ្គត់ផ្គង់ទឹកស្អាត ការបង្ហាញពីវិធានការបង្ការជំងឺផ្សេងៗ ដូចជាជំងឺអេដស៍ រាក គ្រុនគ្រុនចាញ់ ...ជំងឺបណ្តាលមកពីកង្វះមីក្រូសារជាតិ ( អ៊ីយ៉ូដ ដែក វីតាមីនអា...) និង វិធានការអនាម័យ ព្រមទាំងបរិស្ថាន។ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអាហារូបត្ថម្ភ និងសុខភាព អនាម័យ នៅតាមសាលាមត្តេយ្យសិក្សា និង បានបញ្ជ្រាបមេរៀនស្តីពីអាហារូបត្ថម្ភ សុខភាព អនាម័យ គ្រឿងញៀន នៅក្នុងមុខវិជ្ជា

មួយចំនួនដូចជា មុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត សិក្សាសង្គម ចំពោះបឋមសិក្សា និង មុខវិជ្ជាជីវវិទ្យា និង សិក្សាសង្គម ចំពោះមធ្យមសិក្សា ។

ដើម្បីឈានដល់គោលដៅដ៏ធំធេងនេះ ផ្នែកសុខាភិបាល ឬ ផ្នែកអប់រំ តែឯកឯងមិនអាចធ្វើឱ្យសម្រេចបានទេ ហើយទាមទារចាំបាច់តម្រូវឱ្យមានការសហការគ្នាជាពហុវិស័យ ក្រោមបរិបទ " **ការប្រមូលធនធានសំរាប់សុខភាពសិក្សាប្រកបដោយប្រសិទ្ធភាព** " (FRESH) ពិសេសការចូលរួមរបស់ គ្រួសារ សហគមន៍ ស្ថាប័នជាតិ អន្តរជាតិ អ្នកផ្តល់ជំនួយ ដៃគូអភិវឌ្ឍន៍ និង សេវាឯកជនផងដែរ ។

## II. គោលចំណង :

គោលនយោបាយសុខភាពសិក្សា មានគោលបំណងរួមចំណែកលើកកំពស់គុណភាពអប់រំគ្រប់ភូមិសិក្សាដូចខាងក្រោម :

**ក**-លើកកំពស់សុខភាសិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំ នៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និង សហគមន៍ ។

**ខ**-លើកកំពស់សមត្ថភាព និង បំណិនសំខាន់ៗ ក្នុងការបង្ការទប់ស្កាត់ជំងឺនានា និង បង្ការគ្រោះថ្នាក់ផ្សេងៗ ដែលកើតមានជាយថាហេតុក្នុងជីវភាពប្រចាំថ្ងៃ ដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំនៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និង សហគមន៍ ។

**គ**-ជំរុញ និង ផ្តល់ឱកាសឱ្យគ្រប់ផ្នែកពាក់ព័ន្ធ ពិសេសសហគមន៍ឱ្យចូលរួមកាន់តែខ្លាំងឡើងក្នុងការលើកកំពស់សុខភាពសិក្សា ។

**ឃ**-បង្កើនការយកចិត្តទុកដាក់ឱ្យមានសមធម៌ក្នុងការទទួលបានសេវាអប់រំសុខភាព ដល់គ្រប់សមាសភាពពាក់ព័ន្ធ ។

## III. គោលនយោបាយ :

គោលនយោបាយសុខភាពសិក្សា មានចំណុចគោលធំបួនគឺ :

១-ផ្តល់សេវាថែទាំសុខភាពចាំបាច់ ដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំ គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន ដើម្បីធានាបាននូវសមធម៌ក្នុងការអភិវឌ្ឍផ្នែកកាយ សម្បទា បញ្ញាស្មារតី និងសង្គម ។

២-ផ្តល់ការអប់រំសុខភាព និង ផ្តោតលើការប្រាស្រ័យទាក់ទង ដែលនាំឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តគឺជាសមាសភាគដ៏សំខាន់បំផុតក្នុងការផ្តល់ព័ត៌មាន ចំណេះដឹង បំណិន និង បម្រែបម្រួលឥរិយាបថ ទំនួលខុស

ត្រូវ ដើម្បីទទួលបានសុខុមាលភាព និង សុខសុវត្ថិភាព ។

៣-លើកកំពស់បរិស្ថានសិក្សា និង សម្ភាររូបវន្តផ្នែកសុខភាពឱ្យសមស្របតាមស្ថានភាពជាក់ស្តែងតាមកាលៈទេសៈ ទីតាំងភូមិសាស្ត្រ ប្រជាសាស្ត្រ ធានាឱ្យមានប្រសិទ្ធភាព និង គុណភាពអប់រំ ។

៤-បើកទូលាយឱ្យមានការចូលរួមពីក្រសួង ស្ថាប័ន គ្រប់ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិលលើផ្នែកសុខភាពសិក្សា គឺជាការចាំបាច់ ដើម្បីធ្វើឱ្យសាលារៀន សហគមន៍ និងទីសាធារណៈផ្សេងៗ មានអនាម័យសោភណភាព សុវត្ថិភាព និង ផាសុកភាព ។

ដើម្បីសម្រេចគោលនយោបាយសុខភាពសិក្សា ដែលមានចែងខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡាមានយុទ្ធសាស្ត្រ និង យុទ្ធវិធីសម្រាប់អនុវត្តដូចតទៅ :

## គោលនយោបាយ ទី១

**ផ្តល់សេវាថែទាំសុខភាពចាំបាច់ ដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំគ្រប់ គ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន ដើម្បីធានាបាននូវសមធម៌ក្នុងការអភិវឌ្ឍផ្នែកកាយ សម្បទាបញ្ញាស្មារតី និងសង្គម ។**

### យុទ្ធសាស្ត្រ និង យុទ្ធវិធី :

១-គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ត្រូវបង្កើតបទបញ្ជាសុខភាពសិក្សារបស់ខ្លួនមួយដោយផ្អែកលើគោលនយោបាយសុខភាពសិក្សានេះ ដើម្បីអនុវត្តឱ្យបានសមស្របទៅតាមស្ថានភាពពិតជាក់ស្តែងនៅតំបន់របស់ខ្លួន ។

២-ផ្តល់សេវាសុខភាព ត្រូវផ្តោតសំខាន់ទៅលើការពិនិត្យសុខភាព ការផ្តល់វ៉ាក់សាំង មូលដ្ឋានគ្រឹះនៃការសង្គ្រោះបឋម និង ការតាមដានសុខភាពចំពោះសិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំប្រកបដោយលក្ខណៈវេជ្ជសាស្ត្រត្រឹមត្រូវ ដោយសហការជាមួយសេវាសុខាភិបាលសាធារណៈ និង ផ្នែកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់នៅក្នុងមូលដ្ឋានផ្ទាល់ ។

៣-ជំរុញការផ្តល់ថ្នាំបង្ការដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត កុមារពិការ កុមារជួបការលំបាក កុមារនៅតំបន់ដាច់ស្រយាលឱ្យបានត្រឹមត្រូវគ្រប់គ្រាន់តាមក្បួនវេជ្ជសាស្ត្រស្របតាមគោលនយោបាយជាតិនៃការផ្តល់ថ្នាំបង្ការចាប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា ដើម្បីចូលរួមកាត់បន្ថយជំងឺឆ្លងផ្សេងៗ ។

៤-លើកកំពស់ការចុះអន្តរាគមន៍ឱ្យបានទាន់ពេលវេលា លើការទប់ស្កាត់ជំងឺឆ្លង និង ការជួយសង្គ្រោះសិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត កុមារពិការ យុវវ័យជួបការលំបាក យុវវ័យនៅតំបន់ដាច់ស្រយាល

បុគ្គលិកអប់រំ ក្នុងករណីសង្គ្រោះបន្ទាន់ ដូចជាការពុលចំណីអាហារ អាសន្នរោគ ផ្ដាសាយបក្សី ជំងឺរលាកសួតស្រួចស្រាវ (SARS) ការកើតឡើងនូវជំងឺរាតត្បាតផ្សេងៗ ការបំពុលបរិស្ថាន ដើម្បីកាត់បន្ថយគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព ដែលអាចកើតមានឡើងនៅតាមសាលារៀន គ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន និង នៅតាមទីកន្លែងធ្វើការ ។

៥-ជំរុញឱ្យមានការបង្កើតក្លឹបសុខភាព នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីពិនិត្យ និងផ្ដល់ការថែទាំ សុខភាព ពិសេសការជួយសង្គ្រោះបឋម ដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំ ដើម្បីសំរួលឱ្យការជួយសង្គ្រោះទាន់ពេលវេលា ។

៦-លើកកំពស់ការទប់ស្កាត់ការតាបសង្កត់ផ្លូវចិត្ត និង ផ្ដល់សេវាប្រឹក្សាដល់សិស្សមានវិបត្តិផ្លូវចិត្ត ដែលបណ្ដាលមកពីការបំពានលើរាងកាយ ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង បញ្ហាគ្រួសារ និង បញ្ហាមេរោគអេដស៍ និង ជំងឺអេដស៍ ដើម្បីឱ្យសិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត មានជំហរហ៊ានប្រឈមមុខនឹងការតប់ប្រមល់ផ្សេងៗ ដែលកំពុងកើតមានក្នុងឆាកជីវិតរបស់គេ ទាំងនៅក្នុង និងទាំងនៅ ក្រៅគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ។

៧-លើកកំពស់ការផ្ដល់អាហារបំប៉នដល់សិស្សានុសិស្សតាមរយៈ កម្មវិធីផ្ដល់អាហារតាមសាលារៀន និង ពង្រឹងកម្មវិធីអាហារូបត្ថម្ភប្រកបដោយសុវត្ថិភាព ដោយជំរុញឱ្យសិស្សានុសិស្ស ជ្រើសរើសយកការបរិភោគអាហារ ដែលមានសុវត្ថិភាព និង មានសុខភាពល្អ ។

៨-ពង្រឹង ពង្រីកកម្មវិធីសុខភាពមាត់ធ្មេញ ឱ្យបានទូលំទូលាយនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ជាពិសេសតាមសាលាមត្តេយ្យ និង បឋមសិក្សា ស្របតាមកម្មវិធីសិក្សាជាតិ ។

## គោលនយោបាយ ទី២

**ផ្ដល់ការអប់រំសុខភាព និង ផ្ដោតលើការប្រាស្រ័យទាក់ទង ដែលនាំឱ្យមានការផ្លាស់ប្ដូរការប្រព្រឹត្តគឺជាសមាសភាពដ៏សំខាន់បំផុតក្នុងការផ្ដល់ព័ត៌មាន ចំណេះដឹង បំណិន និង បម្រែបម្រួលឥរិយាបថ ទំនួលខុសត្រូវ ដើម្បីទទួលបានសុខុមាលភាព និង សុខសុវត្ថិភាព ។**

### យុទ្ធសាស្ត្រ និង យុទ្ធវិធី :

១-បញ្ចូលរាល់ខ្លឹមសារអប់រំសុខភាព ទៅក្នុងកម្មវិធីសិក្សាគ្រប់កំរិត ទាំងការអប់រំក្នុង និង ក្រៅប្រព័ន្ធ ដោយមានលក្ខណៈទន់ភ្លន់ទៅតាមរចនាសម្ព័ន្ធមូលដ្ឋាន ភូមិសាស្ត្រ ប្រជាសាស្ត្រ និង វប្បធម៌ផងដែរ ពិសេស គឺត្រូវបញ្ជ្រាបទៅក្នុងសៀវភៅសិក្សាគ្រប់កំរិតនូវសារសុខភាព អនាម័យ សុខភាពផ្លូវភេទ សុខភាពបន្តពូជ

ការបង្ការគ្រោះថ្នាក់ (ច្បាប់ចរាចរ) និង ជំងឺផ្សេងៗ ពិសេសការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ។

២-លើកកំពស់ការផ្សព្វផ្សាយ ស្ដីពីសុខភាពផ្លូវភេទ សុខភាពបន្ដពូជអនាម័យ និងការបង្ការគ្រោះថ្នាក់ និង ជំងឺផ្សេងៗ តាមរយៈ ផ្ទាំងរូបភាព ប័ណ្ណផ្ទត់ ឯកសារអំណានបន្ថែម ល្បែងសិក្សា និង ព្រឹត្តិបត្រព័ត៌មានទៅក្នុងកម្មវិធីផ្សេងៗ ដែលមានស្រាប់ដូចជា ការអប់រំកាយ និង កីឡា ការប្រកួតកីឡា ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ការធ្វើសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល រួមទាំងការប្រជុំនានា ។

៣-ពង្រឹង និងពង្រីកចំណេះដឹង ធនធានមនុស្សផ្នែកសុខភាពសិក្សាគ្រប់លំដាប់ថ្នាក់ ដើម្បីធានាបាននូវប្រសិទ្ធភាព គុណភាពទាំងផ្នែកបច្ចេកទេសវេជ្ជសាស្ត្រ ការងារគ្រប់គ្រង ពិនិត្យតាមដាន និង វាយតំលៃ ។

៤-លើកកំពស់សមត្ថភាពមន្ត្រីអប់រំគ្រប់កំរិត តាមរយៈការធ្វើផែនការ ការបើកវគ្គប៉ប៊ន និង វគ្គបណ្ដុះបណ្ដាលផ្សេងៗ ដើម្បីបញ្ជ្រាបខ្លឹមសារចំណេះដឹងស្ដីពីសុខភាព និងបំណិនសមស្របសម្រាប់ការអប់រំផ្សព្វផ្សាយបន្តដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំ និង សហគមន៍ផងដែរ ។

៥-ពង្រឹងការបណ្ដុះបណ្ដាលគ្រូឧទ្ទេស គរុសិស្ស គរុនិស្សិតនៅគ្រប់សាលាគរុកោសល្យ និង គ្រូអក្ខរកម្មជាប់កិច្ចសន្យា អំពីការអប់រំសុខភាព សុខភាពផ្លូវភេទ សុខភាពបន្តពូជ អនាម័យ ការបង្ការគ្រោះថ្នាក់ និង ជំងឺផ្សេងៗ ដើម្បីឱ្យពួកគេមានសមត្ថភាពជំនាញ និង មានទំនុកចិត្តអាចបង្រៀនបន្តប្រកបដោយគុណភាព និង ប្រសិទ្ធភាពខ្ពស់ ។

៦-អប់រំសុខភាពត្រូវផ្ដល់អាទិភាព ជាពិសេសចំពោះការបង្ការជំងឺឆ្លងនានា ដែលកើតមានជាញឹកញាប់នៅក្នុងសហគមន៍ស្របតាមទីតាំងភូមិសាស្ត្រ និង ប្រជាសាស្ត្រ ។

៧-លើកកំពស់សិទ្ធិ និង ជំរុញឱ្យសិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត ទទួលយកឥរិយាបថប្រកបដោយសុវត្ថិភាព តាមរយៈការផ្ដល់ឱកាសឱ្យពួកគេស្គាល់ពីខ្លួនឯង ចេះគ្រប់គ្រងខ្លួន ចេះអប់រំមិត្តភក្តិតាមរយៈ "**កម្មវិធីមិត្តអប់រំមិត្ត**" ពិសេសហាមឃាត់ការរើសអើងចំពោះ អ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍ និងអ្នករងគ្រោះដោយសារជំងឺអេដស៍ នៅគ្រប់ គ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន និង ទីកន្លែង ធ្វើការ ។

៨-ពិនិត្យតាមដាន និង វាយតម្លៃគុណភាពប្រសិទ្ធភាពនៃការអប់រំសុខភាព ដោយសង្កត់ធ្ងន់លើបម្រែបម្រួលអាកប្បកិរិយា និង ធានាបានការកាត់បន្ថយជំងឺ និង គ្រោះថ្នាក់ផ្សេងៗ ។

៩-ជំរុញទប់ស្កាត់ការប្រើប្រាស់ផលិតផលថ្នាំជក់ និង គ្រឿងញៀន គ្រឿងស្រវឹងផ្សេងៗ នៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន ។

## គោលនយោបាយ ទី៣

**លើកកំពស់បរិស្ថានសិក្សា និង សម្ភារូបវន្តផ្នែកសុខភាពឱ្យសមស្របតាមស្ថានភាពជាក់ស្តែងតាមកាលៈទេសៈ ទីតាំងភូមិសាស្ត្រ ប្រជាសាស្ត្រ ធានាឱ្យមានប្រសិទ្ធភាព និង គុណភាពអប់រំ ។**

**យុទ្ធសាស្ត្រ និង យុទ្ធវិធី :**

១-កែលំអបរិស្ថានសិក្សាគ្រប់ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដោយអនុលោមទៅតាមនិយាមគរុកោសល្យត្រឹមត្រូវ ពិសេសគ្រប់គ្រឹះស្ថានសិក្សាទាំងអស់ត្រូវមានទីតាំងអាគារសិក្សាសមស្របសង្ហារិមសិក្សាសមស្របតាមកំពស់ អាយុរបស់សិស្ស និង តម្រូវការពិសេសសម្រាប់កុមារពិការ មានទីធ្លាសម្រាប់សិស្សចេញលេង ទីលានហាត់ប្រាណ និងលេងកីឡា សួនច្បារ សួនដំណាំ ដើមឈើ សម្រាប់ផ្តល់ម្លប់មានប្រភពទឹកស្អាតបង្គន់អនាម័យ កន្លែងលាងដៃ កន្លែងលក់ចំណីអាហារ អន្តេវាសិកដ្ឋាន (បើមាន) ឱ្យមានបរិយាកាសល្អមានពន្លឺគ្រប់គ្រាន់ និង សុវត្ថិភាព ។

២-រៀបចំសណ្តាប់ធ្នាប់តាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដោយជំរុញឱ្យមានបំពាក់នូវសម្ភាររូបវន្តផ្នែកអនាម័យមាន ធុងសំរាម អំបោស ធុងទឹក សាប៊ូ កន្សែងជូតដៃ និង សម្ភាររូបវន្តដទៃទៀតនៅតាមថ្នាក់រៀនសម្រាប់ឱ្យសិស្សអនុវត្តក្បួនអនាម័យជាប្រចាំ ។

៣-រៀបចំបង្គន់អនាម័យ ឬ បន្ទប់ទឹកសមស្របដោយបែងចែកឱ្យដាច់ពីគ្នារវាងបុរស និង ស្ត្រី និងអ្នកពិការ ហើយត្រូវធានាការប្រើប្រាស់ និង មានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់ធ្វើអនាម័យ ។

៤-ជំរុញលើកទឹកចិត្តបុគ្គលិកអប់រំ និង សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត ឱ្យធ្វើពលកម្មសំអាតខាងក្នុង និង ខាងក្រៅបរិវេណ គ្រឹះស្ថានសិក្សា រួមទាំងបែងចែកភារកិច្ចវេនថែទាំសំអាតថ្នាក់រៀន បង្គន់អនាម័យជារៀងរាល់ថ្ងៃ ។

៥-ជំរុញឱ្យបុគ្គលិកអប់រំ គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន លើកកំពស់ការត្រួតពិនិត្យអនាម័យតាមគ្រប់រូបភាព ដូចជាអនាម័យខ្លួនប្រាណ និងការត្រួតពិនិត្យអនាម័យចំណីអាហារ ដែលដាក់លក់នៅតាមគ្រឹះស្ថានសិក្សាគ្រប់កំរិត ដើម្បីកាត់បន្ថយសារធាតុគីមីពុលប៉ះពាល់ដល់សុខភាព និង ជំងឺឆ្លងផ្សេងៗ ប្រកបដោយប្រសិទ្ធភាព ។

៦-រៀបចំកន្លែងចោលសំរាម និង កាកសំណល់ផ្សេងៗ ឱ្យសមស្រប ចៀសវាងការរំខានដល់ការសិក្សា

រៀនសូត្ររបស់សិស្ស និស្សិត គរុសិស្ស គរុនិស្សិត ពិសេសហាមឃាត់ដាច់ខាតការជុតសំរាម និង ការគរសំរាម ក្បែរថ្នាក់រៀន ។

៧-លើកកំពស់ការប្រារព្ធទិវាអនាម័យ ឬ ការប្រឡងប្រណាំង សាលារៀនស្អាត ថ្នាក់រៀនស្អាត និង មានអនាម័យ ពិសេសការបិទផ្សាយនូវសារសុខភាព ដែលទាក់ទងនឹងបរិស្ថានសិក្សានៅគ្រប់គ្រឹះស្ថានសិក្សា សាធារណៈ និងឯកជន ។

៨-ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកសុខភាពសិក្សាគ្រប់លំដាប់ថ្នាក់ លើការពិនិត្យតាមដានវិធានការ អនាម័យ និង ការលើកកំពស់បរិស្ថានសិក្សានៅគ្រប់ គ្រឹះស្ថានសិក្សាគ្រប់កំរិត ។

៩-ជំរុញទប់ស្កាត់ការប្រើប្រាស់ផលិតផលថ្នាំជក់ និង គ្រឿងញៀនផ្សេងៗ នៅតាមគ្រឹះស្ថានសិក្សា សាធារណៈ និង ឯកជន ។

## គោលនយោបាយ ទី៤

**បើកទូលាយឱ្យមានការចូលរួមពីក្រសួង ស្ថាប័ន គ្រប់ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិលលើផ្នែក សុខភាពសិក្សា គឺជាការចាំបាច់ ដើម្បីធ្វើឱ្យសាលារៀន សហគមន៍ និងទីសាធារណៈផ្សេងៗ មានអនាម័យ សោភណភាព សុវត្ថិភាព និង ផាសុកភាព ។**

**យុទ្ធសាស្ត្រ និង យុទ្ធវិធី :**

១-ពង្រឹងយន្តការសម្របសម្រួលអន្តរក្រសួង និង រៀបចំក្រុមការងារលើកកំពស់សុខភាពតាមសាលា រៀន នៅថ្នាក់ក្រសួង និង ខេត្ត ក្រុង ដោយមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ រួមមានក្រសួងកសិកម្ម អភិវឌ្ឍន៍ជនបទ ផែនការ ហិរញ្ញវត្ថុ បរិស្ថាន កិច្ចការនារី ពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល) សុខាភិបាល អាជ្ញាធរដែនដី អង្គការអន្តរជាតិ អ្នកផ្តល់ជំនួយ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និង អង្គការសង្គម ស៊ីវិលនានា ដែលធ្វើការងារទាក់ទងនឹងសុខភាពសិក្សា ។

២-ជំរុញរៀបចំបង្កើតគណៈកម្មការសុខភាពសិក្សានៅតាម គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដោយមានសមាសភាពចូលរួមពី នាយកគ្រឹះស្ថានសិក្សា គ្រូបង្គោលអនាម័យ មន្ត្រីមណ្ឌលសុខភាពសមាគម មាតាបិតាសិស្ស អាជ្ញាធរដែនដី និង សិស្សានុសិស្ស ។

៣-ពង្រីកកិច្ចសហការជាមួយដៃគូពាក់ព័ន្ធនានា ដើម្បីពង្រឹងភាពម្ចាស់ការលើការងារលើកកំពស់ សុខភាព ដោយជំរុញឱ្យមានការផ្លាស់ប្តូរព័ត៌មានពីគ្នាទៅវិញទៅមកជាទៀងទាត់ ស្តីពីការប្រជុំធ្វើផែនការ ផ្លាស់ប្តូរបទពិសោធ នៃការអនុវត្តសកម្មភាព ការពិនិត្យតាមដាន និង ការវាយតម្លៃ ។

៤-បើកទូលាយឱ្យមានការចូលរួមពីផ្នែកឯកជន លើការងារថែរក្សាអនាម័យ ការអប់រំសុខភាព និង ការបង្ការជំងឺនានា យោលទៅតាមភូមិសាស្ត្រ ប្រជាសាស្ត្រ ដើម្បីរួមចំណែកកាត់បន្ថយអត្រាបោះបង់ការសិក្សា និង អត្រាត្រួតថ្នាក់របស់សិស្សានុសិស្ស ។

៥-ជំរុញសហគមន៍ ពិសេសគណៈកម្មការទ្រទ្រង់សាលារៀន សមាគមមាតាបិតាសិស្ស សិស្សានុសិស្ស និង បុគ្គលិកអប់រំ ឱ្យមានភាពសកម្ម ដើម្បីចូលរួមបំផុសរៀបចំធ្វើអនាម័យ ការបង្ការជំងឺឆ្លងនានា ពិសេស ការបង្ការមេរោគអេដស៍ និង ជំងឺអេដស៍ និង ជួយសង្គ្រោះដល់កុមារងាយរងគ្រោះ និង កុមារទីទ័លក្រ ។

៦-ជំរុញ និង ផ្តល់ឱកាសឱ្យសិស្សានុសិស្ស និង មាតាបិតាសិស្ស ចូលរួមក្នុងការងារលើកកំពស់ សុខភាព តាមរយៈការចូលរួមផ្តល់មតិក្នុងសិក្ខាសាលា និង ការប្រជុំនានា ស្តីពីការធ្វើផែនការ ការពិនិត្យ តាមដាន និង ការវាយតម្លៃ ។

## IV. អវសានកថា :

គោលនយោបាយសុខភាពសិក្សានេះ ធានាធ្វើឱ្យគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន មានបរិស្ថាន រូបវន្តប្រកបដោយសុវត្ថិភាព និង ធានាទូវសិទ្ធិ និង ឱកាសស្មើគ្នាក្នុងការផ្តល់សេវាអប់រំសុខភាព និង សេវា សុខាភិបាលទៀងទាត់ និង ផ្តល់ប្រយោជន៍ដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត និង បុគ្គលិកអប់រំ នូវសក្តានុពលសុខភាព ដើម្បីចូលរួមចំណែកលើកកំពស់គុណភាពអប់រំ ស្របតាមផែនការជាតិ អប់រំសម្រាប់ ទាំងអស់គ្នា គោលដៅអភិវឌ្ឍសហស្សវត្ស និង គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា ស្ថាប័នពាក់ព័ន្ធទាំងអស់ មន្ត្រី និង បុគ្គលិកអប់រំគ្រប់ក៏រិត សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិតនៅតាមគ្រឹះស្ថានសាធារណៈ និង ឯកជន គ្រួសារ សហគមន៍ អង្គការជាតិ- អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់ជំនួយ ដៃគូអភិវឌ្ឍនឹងចូលរួមយកចិត្តទុកដាក់អនុវត្ត **គោល នយោបាយសុខភាពសិក្សា** នេះ ឱ្យទទួលបានជោគជ័យ និង ប្រកបដោយប្រសិទ្ធភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**បណ្ឌិត កុល ពេង**

**អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)** គឺជាអង្គការបណ្ដាញ ដែលលើកកម្ពស់ កិច្ចសហប្រតិបត្តិការឲ្យបានសកម្មរវាងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការក្នុងវិស័យអប់រំ និងធ្វើការស្វែងរកការគាំទ្រមតិក្នុងនាមតំណាងឲ្យអង្គការជាសមាជិករបស់ខ្លួន តាមរយៈកិច្ចប្រជុំ និងពិភាក្សាគោលនយោបាយ ជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល មានសមាជិកជាង ១៤០ ដែលជាអង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើការលើវិស័យអប់រំនៅកម្ពុជា ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)
អសយដ្ឋាន៖ ផ្ទះលេខ ៤១ ផ្លូវលេខ ៤៦៤ សង្កាត់ ទួលទំពូង ២
ខណ្ឌ ចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ។
អ៊ីមេល៖ info@nepcambodia.org
ទូរស័ព្ទ៖ ០២៣ ២២៤ ៧៧៤
គេហទំព័រ៖ www.nepcambodia.org